ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ..១២..អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ឯកសណ្ឋាន ស្លាកសញ្ញា និង ទង់ជ័យ នៃកងយោធពលខេមរភូមិន្ទ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ

-បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ

-បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ

-បានឃើញអនុក្រឹត្យលេខ ២៩អនក្រ.បក ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០០២ ស្តីពីបទវិន័យទូទៅសម្រាប់កងយោធពលខេមរភូមិន្ទ

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលបំណងរៀបចំចងក្រងឡើងវិញឯកសណ្ឋាន ស្លាកសញ្ញា បរិក្ខារូមផ្សំ និងទង់ជ័យនៃកងយោធពលខេមរភូមិន្ទ។

**មាត្រា ២.-**

អនុក្រឹត្យនេះមានគោលដៅកំណត់ឯកសណ្ឋាន ស្លាកសញ្ញា បរិក្ខារូមផ្សំ និងទង់ជ័យតាមប្រភេទកងទ័ពនិងបណ្តាទ័ពជំនាញនៃកងយោធពលខេមរភូមិន្ទ។

## ជំពូកទី២
## ឯកសណ្ឋាននិងស្លាកសញ្ញាកងទ័ពជើងគោក

**មាត្រា ៣.-**

ត្រូវបានរៀបចំឯកសណ្ឋានធំលេខ១ សម្រាប់កងទ័ពជើងគោកដែលមានរូបភាព និងម៉ូដដូចខាងក្រោម៖

១- ឯកសណ្ឋានថ្នាក់ឧត្តមសេនីយ៍

-អាវកុដពណ៌ស កត្រង់ កាត់រាងអាវធំ គ្មានឆែកខ្នង កអាវមានកម្ពស់ ៥ស.ម ដោយប៉ាក់ភ្ញីទេសពណ៌មាសជុំវិញតួកអាវ និងប៉ាក់ផ្កាភ្ញីរាងកន្ទុយកណ្ដុរព័ទ្ធជុំវិញមានទំហំ ៣ម.ម។ លើស្មាទាំងសងខាងមានប៉ូលមានហោប៉ៅបួន(ហោប៉ៅទាំង២ខាងលើដេរប៉ះចំកណ្តាល មានចាប់ផ្នត់មួយ គម្របរាងស្លឹកពោធិ ហោប៉ៅ២ខាងក្រោមដេរបង្កប់ គម្របរាងចតុកោណកែង) អាវដៃវែងកាត់ម៉ូដដៃបំពង់ នៅចុងដៃអាវមានបត់ និងប៉ាក់ភ្ញីទេសពណ៌មាសរាងស្លឹកពោធិ ហើយចុងស្លឹកពោធិនោះត្រូវដាក់ឲ្យចំលើខ្នងដៃ។ ទំហំប៉ាក់ចាប់ពីចុងដៃអាវរហូតដល់ចុងស្លឹកពោធិមានកម្ពស់ ៩ស.ម ផ្នែកខាងក្រោយចុងដៃអាវកម្ពស់ ៨.៥ស.ម។ នៅជុំវិញភ្ញីទេសប៉ាក់ផ្កាភ្ញីរាងកន្ទុយកណ្តុរព័ទ្ធជុំវិញមានទំហំ ៣ម.ម។ ឡេវអាវពណ៌មាសមានរូបព្រះសង្ហារ ចាប់ពីកអាវមកដល់ក្រោមមានចំនួន៦គ្រាប់អង្កត់ផ្ចិត ២៥ម.ម ឡេវហោប៉ៅពីរខាងលើមានអង្កត់ផ្ចិត ១៥ម.ម ឡេវហោប៉ៅពីរខាងក្រោមមានអង្កត់ផ្ចិត ២០ម.ម នៅចុងដៃអាវនីមួយៗមានដាក់ឡេវបញ្ឆោតចំនួន៣ម្ខាង អង្កត់ផ្ចិត ១៥ម.ម និងប៉ូលស្មាដាក់ឡេវជ័រមានអង្កត់ផ្ចិត ១៨ម.ម

-ខោជើងវែងពណ៌ខ្មៅ ចង្កេះតគ្មានភ្លី មានហោប៉ៅក្រោយមួយដេរបង្កប់គ្មានគម្រប ហោប៉ៅចំហៀងដេរបង្កប់តាមថ្នេរខោទាំងសងខាងចាប់ពីចង្កេះដល់ចុងជើង ខោមានឆ្នូតពណ៌ក្រហម២ (ឆ្នូតនីមួយៗមានទំហំ២ស.ម ឃ្លាតពីគ្នា ០.៥ស.ម)

-មួកកាស្កេតផលិតពីក្រណាត់កម្ចីពណ៌ខ្មៅ ខាងមុខមានរូបព្រះសង្ហារធ្វើពីលោហធាតុពណ៌មាសជើងមួកពណ៌ក្រហម ហាមមួកធ្វើពីជ័រវែងពណ៌ខ្មៅ មានក្បាច់ភ្ញីទេសធ្វើពីលោហធាតុពណ៌មាសដល់ចុងហាមមួក (ចំកណ្តាលមានកម្ពស់ ៣២ម.ម) វណ្ឌខាងមុខធ្វើពីខ្សែលោហធាតុវេញចូលគ្នាពណ៌មាសទំហំ២០ម.ម និងឡេវពណ៌មាសមានរូបព្រះសង្ហារមានអង្កត់ផ្ចិត ១៨ម.ម

-ស្បែកជើងស្បែក កខ្លីពណ៌ខ្មៅចងខ្សែ ស្រោមជើងពណ៌ខ្មៅ និងស្រោមដៃពណ៌ស

-ខ្សែឥស្សរិយយសពណ៌មាសវេញចូលគ្នារាងសំប៉ែតទំហំ ២ស.ម ប្រវែង៦៥ ទៅ៧៥ស.ម ខ្សែអមបីមានម្ជុលបន្តោកពីរពណ៌មាស ខ្សែក្រវ៉ាត់ពណ៌គ្រែអ៊ី ក្បាលខ្សែក្រវ៉ាត់ធ្វើពីលោហធាតុលាតពណ៌មាស។

ចំពោះនារី អាវមានគំរូដូចបុរសតែកាត់តាមរាងដងខ្លួន និងសំពត់ហ្ស៊ីបក្រោមជង្គង់ពណ៌ខ្មៅមាន

ឆ្នូតក្រហមសងខាងដូចគ្នា។

២. ឯកសណ្ឋានថ្នាក់វរសេនីយ៍

រូបភាព ម៉ូដប្រភេទឯកសណ្ឋានដូចថ្នាក់ឧត្តមសេនីយ៍ តែត្រូវបានកំណត់មួយចំនួនដូចខាងក្រោម៖

ប៉ាក់ភ្ជីទេសនៅខាងដើមកអាវ ទំហំ៣ស.ម ហើយបញ្ជិតទៅលើប្រវែង ៧ស.ម ដោយគិតពីខាងដើមកអាវ។ នៅចុងដៃអាវមានប៉ាក់ភ្ជីទេសដូចថ្នាក់ឧត្តមសេនីយ៍ដែរ តែទំហំតូចជាងពាក់កណ្តាល។ ខោមានឆ្នូតក្រហមពីរ ទំហំ១ស.ម។មួកកាស្កេតមានក្បាច់ភ្ជីទេស ខាងចុងមួកទុកចន្លោះពីជើងមួកសងខាងប្រវែង៦ស.ម (ចំកណ្តាលមានកម្ពស់ ៣២ម.ម) វ័ណ្ឌខាងមុខទំហំ ១២ម.ម និងឡេវនៅចុងវ័ណ្ឌសងខាងដូចថ្នាក់ឧត្តមសេនីយ៍។ ខ្សែឥស្សរិយយសវេញចូលគ្នាបីខ្សែទំហំ ១.២ស.ម។

ចំពោះនារី អាវមានគំរូដូចបុរសតែកាត់តាមរាងដងខ្លួន និងសំពត់ហ្ស៊ីបក្រោមជង្គង់ពណ៌ខ្មៅមានឆ្នូតក្រហមសងខាងដូចគ្នា។

៣. ឯកសណ្ឋានថ្នាក់អនុសេនីយ៍

រូបភាព ម៉ូដ ប្រភេទឯកសណ្ឋានដូចថ្នាក់ឧត្តមសេនីយ៍ដែរ តែត្រូវបានកំណត់មួយចំនួនដូចខាងក្រោម៖

ប៉ាក់ភ្ជីទេសនៅខាងដើមកអាវទំហំ ២ស.ម ហើយបញ្ជិតរៀវស្តួចឡើងប្រវែង ៧ស.ម ថ្នេរចុងដៃអាវមានឆ្នូតពណ៌មាសទំហំ១ស.ម។ មួកកាស្កេត នៅខាងលើតែមហាមមួកមានឆ្នូតពណ៌មាស ទទឹងឆ្នូតទំហំ ៦ម.ម ខ្សែវ័ណ្ឌដូចថ្នាក់វរសេនីយ៍។ ខោជើងវែងពណ៌ខ្មៅមានឆ្នូតក្រហមតែមួយ ទទឹង២ស.ម។

ចំពោះនារី អាវមានគំរូដូចបុរសតែកាត់តាមរាងដងខ្លួន និងសំពត់ហ្ស៊ីបក្រោមជង្គង់ពណ៌ខ្មៅមានឆ្នូតក្រហមសងខាងដូចគ្នា។

**មាត្រា ៤.-**

ត្រូវបានរៀបចំឯកសណ្ឋានធំលេខ២ សម្រាប់កងទ័ពជើងគោកដែលមានរូបភាព និងម៉ូដដូចខាងក្រោម៖

១. ឯកសណ្ឋានថ្នាក់ឧត្តមសេនីយ៍

ខោអាវពណ៌គ្រេអ៊ី អាវសឺមីក្នុងពណ៌កាគីខ្ចី ក្រវ៉ាត់កពណ៌ខ្មៅ។

-អាវ មាននែកខ្នងមួយ កបើកមានប៉ូលស្មា ហោប៉ៅបួន (ហោប៉ៅខាងលើពីរដេរប៉ះចំកណ្តាលមានចាប់ផ្នត់មួយគម្របរាងស្លឹកពោធិ ហោប៉ៅពីរខាងក្រោមដេរបង្កប់មានគម្របរាងចតុកោណកែង) ដៃអាវវែងកាត់រាងបំពង់។ ឡេវអាវពណ៌មាសមានរូបព្រះសង្ហារ ពីកអាវមកដល់ក្រោមមានឡេវចំនួន៤គ្រាប់ មានអង្កត់ផ្ចិត២៥ម.ម ឡេវហោប៉ៅលើពីរមានអង្កត់ផ្ចិត១៥ម.ម ឡេវហោប៉ៅពីរខាងក្រោមមានអង្កត់ផ្ចិត ២០ម.ម ឡេវបញ្ឆោតចុងដៃអាវម្ខាងបីមានអង្កត់ផ្ចិត ១៥ម.ម និងប៉ូលស្មាដាក់ឡេវជ័រមានអង្កត់ផ្ចិត ១៨ម.ម

-ខោជើងវែងពណ៌គ្រេអ៊ី ចង្កេះតគ្មានក្លី ហោប៉ៅបួន (ហោប៉ៅពីរខាងក្រោយដេរបង្កប់មានគម្របរាងស្លឹកពោធិ ហោប៉ៅពីរចំហៀងដេរបង្កប់តាមថ្នេរខោទាំងសងខាង)

-មួកកាស្កេតពណ៌គ្រេអ៊ី ជើងមួកពណ៌ខ្មៅ ហាមមួកធ្វើពីជ័ររឹងពណ៌ខ្មៅ វ័ណ្ឌខាងមុខធ្វើអំពីខ្សែលោហធាតុវេញចូលគ្នាពណ៌មាសទំហំ២០ម.ម និងឡេវមានរូបព្រះសង្ហារមានអង្កត់ផ្ចិត១៨ម.មធ្វើពីលោហធាតុពណ៌មាស លើហាមមួកមានក្បាច់ភ្ជីទេសធ្វើពីលោហធាតុពណ៌មាសដល់ចុងហាមមួកទាំងសងខាង (ចំកណ្តាលមានកម្ពស់ ៣២ម.ម)

-អាវសឺមីដៃវែង កឧប កាត់ស្រុងដាក់ក្នុងខោ មានហោប៉ៅមួយនៅខាងឆ្វេងដៃអាវកាត់នែកដាក់

ខ្សែរចុងដៃ

-ស្រោមដៃពណ៌ស ស្បែកជើងស្បែក កខ្លីពណ៌ខ្មៅចងខ្សែ ខ្សែក្រវ៉ាត់ពណ៌ត្រែអ៊ី ក្បាលធ្វើអំពីលោហធាតុលាតពណ៌មាស។

ចំពោះនារី អាវមានគំរូដូចបុរសតែកាត់តាមរាងដងខ្លួន និងសំពត់ហ្ស៊ីបក្រោមជង្គង់។

២. ឯកសណ្ឋានថ្នាក់វរសេនីយ៍

រូបភាព ម៉ូដ ប្រភេទឯកសណ្ឋានដូចថ្នាក់ឧត្តមសេនីយ៍ តែត្រូវបានកំណត់នៅត្រង់ហាមមួកក្បាច់ភ្ញីទេសទុកចន្លោះពីជើងហាមមួកសងខាង៦ស.ម។

ចំពោះនារី អាវមានគំរូដូចបុរសតែកាត់តាមរាងដងខ្លួន និងសំពត់ហ្ស៊ីបក្រោមជង្គង់។

៣. ឯកសណ្ឋានថ្នាក់អនុសេនីយ៍

រូបភាព ម៉ូដ ប្រភេទឯកសណ្ឋានដូចថ្នាក់ឧត្តមសេនីយ៍ តែត្រូវបានកំណត់នៅត្រង់ហាមមួកគ្មានក្បាច់ភ្ញីទេសទេ តែមានឆ្នូតពណ៌មាសនៅលើគែមហាមមួក។

ចំពោះនារី អាវមានគំរូដូចបុរសតែកាត់តាមរាងដងខ្លួន និងសំពត់ហ្ស៊ីបក្រោមជង្គង់។

សម្រាប់នាយទាហានរង និងពលទាហាននៅពេលបំពេញបេសកកម្មក្រៅប្រទេស ឬក្នុងពិធីការជាតិធំៗអាចមានឯកសណ្ឋានធំលេខ២ដែរ ហើយឯកសណ្ឋាននោះដូចគ្នាថ្នាក់អនុសេនីយ៍ តែមួកកាស្កេតគ្មានក្បាច់ភ្ញីទេសឬឆ្នូតអ្វីទាំងអស់។

**មាត្រា ៥**.-

ត្រូវបានរៀបចំឯកសណ្ឋានលេខ៣ សម្រាប់កងទ័ពជើងគោកដែលមានរូបភាព និងម៉ូដដូចខាងក្រោម៖

១.ឯកសណ្ឋានថ្នាក់ឧត្តមសេនីយ៍

-ខោអាវពណ៌ត្រែអ៊ី មួកកាស្កេតពណ៌ត្រែអ៊ី

-អាវដៃខ្លី កបើក ខាងក្រោយមានផែកនិងប៉ានចង្កេះ ផ្នែកខាងមុខមានហោប៉ៅបួន(ខាងលើ២និងខាងក្រោម២ មានគម្របដេររាងមូល) ហោប៉ៅនីមួយៗចាប់ផ្នត់មួយចំកណ្តាល មានប៉ូលស្មាដាក់ឡេវដែរមានអង្កត់ផ្ចិត១៨ម.ម។ ចាប់ពីកអាវមកដល់ក្រោមមានឡេវចំនួន៥គ្រាប់មានអង្កត់ផ្ចិត២០ម.ម ឡេវហោប៉ៅលើ២គ្រាប់មានអង្កត់ផ្ចិត ១៥ម.ម និងឡេវហោប៉ៅក្រោម២គ្រាប់មានអង្កត់ផ្ចិត ១៨ម.ម ឡេវមានរូបព្រះសង្ហារធ្វើពីលោហធាតុពណ៌មាស

-អាវយឺតក្នុងដៃខ្លី ពណ៌ត្រែអ៊ី

-ខោជើងវែង មួក ស្បែកជើងនិងស្រោមជើងដូចឯកសណ្ឋានធំលេខ២។

ចំពោះនារីអាវដូចបុរសតែកាត់តាមរាងដងខ្លួន និងសំពត់ហ្ស៊ីបពណ៌ត្រែអ៊ីក្រោមជង្គង់។

២.ឯកសណ្ឋានថ្នាក់វរសេនីយ៍

ឯកសណ្ឋានដូចថ្នាក់ឧត្តមសេនីយ៍ដែរ តែត្រូវបានកំណត់នៅត្រង់ហាមមួកក្បាច់ភ្ញីទេសទុកចន្លោះពីជើងមួកសង ខាង ៦ស.ម។

ចំពោះនារី អាវមានគំរូដូចបុរសតែកាត់តាមរាងដងខ្លួន និងសំពត់ហ្ស៊ីបក្រោមជង្គង់។

៣.ឯកសណ្ឋានថ្នាក់អនុសេនីយ៍

ឯកសណ្ឋានដូចថ្នាក់ឧត្តមសេនីយ៍ដែរតែត្រូវបានកំណត់នៅត្រង់ហាមមួកគ្មានក្បាច់ភ្ញីទេសទេមានឆ្នូតពណ៌មាសនៅលើគែមហាមមួក។

ចំពោះនារី អាវមានគំរូដូចបុរសតែកាត់តាមរាងដងខ្លួន និងសំពត់ហ្ស៊ីបក្រោមជង្គង់។

សម្រាប់នាយទាហានរងនិងពលទាហាន នៅពេលបំពេញបេសកកម្មក្រៅប្រទេស ឬក្នុងពិធីការជាតិធំៗ អាចមានឯកសណ្ឋានលេខ៣ដែរ ហើយឯកសណ្ឋាននោះដូចគ្នាថ្នាក់អនុសេនីយ៍ តែមួកកាស្កេតគ្មានក្បាច់ភ្ញីទេសឬឆ្នូតអ្វីទាំងអស់។

**មាត្រា ៦.-**

ត្រូវបានរៀបចំឯកសណ្ឋានលេខ៤ សម្រាប់កងទ័ពជើងគោកដែលមានរូបភាព និងម៉ូដដូចខាងក្រោម៖

១.ឯកសណ្ឋានថ្នាក់ឧត្តមសេនីយ៍

-អាវដៃវែងពណ៌ក្រែម៉ កឌុបមានប៊ូលស្នាកាត់ស្រុងវែងដាក់ក្នុងខោ ហោប៉ៅពីរដេរប៉ះ ចំកណ្ដាលដេរបត់ផ្នត់មួយមានគម្របរាងស្លឹកពោធិ ខ្សែរពណ៌ក្រែម៉ីមានអង្កត់ផ្ចិត១៨ម.ម នៅចុងដៃអាវមានដែកនិងដាក់ខ្សែរ

-ខោជើងវែងពណ៌ក្រែម៉ី ដូចឯកសណ្ឋានលេខ២

-មួកហ្សិកកីពណ៌ក្រែម៉ី នៅខាងមុខមានប៉ាក់រូបព្រះសង្ហារពណ៌មាស លើហាមមួកមានប៉ាក់ក្បាច់ផ្កាភ្ញីទេសពីអំបោះពណ៌មាសពីចុងម្ខាងដល់ចុងម្ខាង(ចំកណ្ដាលមានកម្ពស់៣២ម.ម)។ ខ្សែក្រវ៉ាត់ ស្បែកជើងស្រោមជើងដូចឯកសណ្ឋានលេខ២

-មួកបេរេពណ៌ក្រែម៉ី (ទ័ពពិសេសឆត្រយោងពណ៌ក្រហម ទ័ពការពារព្រំដែនពណ៌បៃតង មជ្ឈមណ្ឌលជាតិគ្រប់គ្រងកងកម្លាំងរក្សាសន្តិភាព បោសសំអាតមីន និងកាកសំណល់សង្គ្រាមពណ៌ខៀវដូចមួកអង្គការសហប្រជាជាតិ)។

ចំពោះនារីអាវដូចបុរសតែកាត់តាមរាងដងខ្លួន ខោជើងវែងឬសំពត់ហ្ស៊ីបក្រោមជង្គង់។

២. ឯកសណ្ឋានថ្នាក់វរសេនីយ៍

រូបភាព ម៉ូដ ប្រភេទឯកសណ្ឋានដូចថ្នាក់ឧត្តមសេនីយ៍ដែរ តែត្រូវបានកំណត់នៅត្រង់មួកហ្សិកកីក្បាច់ភ្ញីទេសនៅលើហាមមួកទុកចន្លោះ៥ស.មពីជើងមួក។

ចំពោះនារី អាវមានគំរូដូចបុរសតែកាត់តាមរាងដងខ្លួន ខោជើងវែងឬសំពត់ហ្ស៊ីបក្រោមជង្គង់។

៣. ឯកសណ្ឋានថ្នាក់អនុសេនីយ៍

រូបភាព ម៉ូដ ប្រភេទឯកសណ្ឋានដូចថ្នាក់ឧត្តមសេនីយ៍ដែរ តែត្រូវបានកំណត់នៅត្រង់មួកហ្សិកកីគ្មានក្បាច់ភ្ញីទេសនៅលើហាមមួកទេ តែមានឆ្នូតពណ៌មាសលើគែមហាមមួក។

ចំពោះនារី អាវមានគំរូដូចបុរសតែកាត់តាមរាងដងខ្លួន ខោជើងវែងឬសំពត់ហ្ស៊ីបក្រោមជង្គង់។

៤. ឯកសណ្ឋានថ្នាក់នាយទាហានរងនិងពលទាហាន

រូបភាព ម៉ូដ ប្រភេទឯកសណ្ឋានដូចថ្នាក់ឧត្តមសេនីយ៍ដែរតែត្រង់មួកហ្សិកកីនៅលើហាមមួកគ្មានក្បាច់ភ្ញីទេសឬឆ្នូតអ្វីទាំងអស់។

ចំពោះនារី អាវមានគំរូដូចបុរសតែកាត់តាមរាងដងខ្លួន ខោជើងវែងឬសំពត់ហ្ស៊ីបក្រោមជង្គង់។

**មាត្រា ៧.-**

ត្រូវបានរៀបចំឯកសណ្ឋានលេខ៥ សម្រាប់កងទ័ពជើងគោកដែលមានរូបភាព និងម៉ូដដូចខាងក្រោម៖

១. ឯកសណ្ឋានថ្នាក់ឧត្តមសេនីយ៍

គំរូឯកសណ្ឋានលេខ៥មានតែមួយប្រភេទ ខោអាវប៉ាក់ក្រឡាធំ។

-អាវដៃវែង កបើកថ្នេរឧប មានប៉ូលស្មា ហោប៉ៅបួនដេរយោគមានគម្របរាងចតុកោណកែងឡេវដ័រពណ៌ត្រែអ៊ីមានអង្កត់ផ្ចិត២០ម.មដាក់បង្កប់ទាំងអស់ ចុងដៃអាវរាងបំពង់មានក្រវ៉ាត់

-ខោជើងវែង ថ្នេរឧបហោប៉ៅក្រោយពីរដេរបង្កប់មានគម្របរាងចតុកោណកែងនៅចំហៀងតាមថ្នេរខោមានហោប៉ៅបញ្ឆិត ប៉ានជង្គង់ ប៉ានគូទ នៅសងខាងភ្លៅមានហោប៉ៅយោគធំពីរ។ នៅចំកណ្តាលហោប៉ៅមានបត់ផ្នត់ពីរជាន់គម្របរាងចតុកោណកែង ហោប៉ៅនីមួយៗមានឡេវដ័រពីរគ្រាប់ពណ៌ត្រែអ៊ីមានអង្កត់ផ្ចិត២០ម.ម ហើយដាក់បង្កប់ទាំងអស់ ជើងខោចងខ្សែឬខ្សែយឺត

-មួកដែកឬមួកហ្សិកកីប៉ាក់ នៅលើហាមមួកហ្សិកកីមានប៉ាក់ក្បាច់ភ្ញីទេសពីអំបោះពណ៌មាសដល់ចុងហាមមួក (ចំកណ្តាលមានកម្ពស់ ៣២ម.ម)។ នៅផ្នែកខាងមុខមានប៉ាក់ភ្ជាប់រូបព្រះសង្ហារពីអំបោះពណ៌មាសកម្ពស់៥ស.ម ទទឹង៥ស.ម យកតាមសញ្ញាជាតិ

-មួកបេរ៉េពណ៌ត្រែអ៊ី (ទ័ពពិសេសឆត្រយោងពណ៌ក្រហម ទ័ពការពារព្រំដែនពណ៌បៃតង មជ្ឈមណ្ឌលជាតិគ្រប់គ្រងកងកម្លាំងរក្សាសន្តិភាព បោសសំអាតមីន និងកាកសំណល់សង្គ្រាមពណ៌ខៀវដូចមួកអង្គការសហប្រជាជាតិ)

-ស្បែកជើងកវែងប៉ាក់ ឬពណ៌ខ្មៅ ខ្សែក្រវ៉ាត់តូចពណ៌ត្រែអ៊ី ស្រោមជើងពណ៌ត្រែអ៊ី និងខ្សែសាំងទៀរ៉ុងពណ៌ត្រែអ៊ី។

ចំពោះទ័ពពិសេសឆត្រយោងប្រើឯកសណ្ឋានប៉ាក់ក្រឡាតូច។

២. ឯកសណ្ឋានថ្នាក់វរសេនីយ៍

រូបភាព ម៉ូដ ឯកសណ្ឋានដូចថ្នាក់ឧត្តមសេនីយ៍ តែខុសគ្នាត្រង់មួកហ្សិកកីមានក្បាច់ភ្ញីទេសនៅហាមមួកទុកចន្លោះ៥ស.មពីជើងមួក។

៣. ឯកសណ្ឋានថ្នាក់អនុសេនីយ៍

រូបភាព ម៉ូដ ឯកសណ្ឋានដូចថ្នាក់ឧត្តមសេនីយ៍ តែខុសគ្នាត្រង់មួកហ្សិកកិមានឆ្នូតពណ៌មាសលើគែមហាមមួក។

៤.ឯកសណ្ឋានថ្នាក់នាយទាហានរងនិងពលទាហាន

រូបភាព ម៉ូដ ឯកសណ្ឋានដូចថ្នាក់ឧត្តមសេនីយ៍ តែខុសគ្នាត្រង់មួកហ្សិកកីគ្មានក្បាច់ភ្ញីទេស ឬឆ្នូតអ្វីទាំងអស់នៅលើហាមមួក។

**មាត្រា ៨.-**

ត្រូវបានរៀបចំឯកសណ្ឋានជំនាញបច្ចេកទេស សម្រាប់ប្រភេទទ័ពជំនាញជើងគោកដូចខាងក្រោម៖

១- កងទ័ពរថក្រោះ រថពាសដែក

ឯកសណ្ឋានពណ៌ខ្មៅ (ម៉ូដដូចឯកសណ្ឋានលេខ៥ទ័ពជើងគោក) មួកបេរ៉េពណ៌ខ្មៅ ស្បែកជើងកវែង និងស្រោមជើងពណ៌ខ្មៅ។

២- គ្រឿងយន្តវិស្វកម្ម និងអ្នកបម្រើការពេងជាងជួសជុលឬសិប្បកម្មយោធា

-ឯកសណ្ឋានពណ៌ខៀវ អាវដៃវែង ក្រវ៉ាត់ចង្កេះ ទំហំ ៦ស.ម ដៃអាវដេររាងបំពង់មានក្រវ៉ាត់ដាក់ឡេវ ហោប៉ៅពីរដេរយោគ គម្របរាងចតុកោណកែងដេរបង្កប់

-ខោជើងវែងចង្កេះតគ្មានភ្លី ហោប៉ៅក្រោយដេរបង្កប់ គម្របរាងស្លឹកពោធិនិងមានហោប៉ៅចំហៀងពីរ

ដេរបង្កប់តាមថ្នេរខោ ឡេវបង្កប់ថ្នេរឌុប ពាក់មួកហ្សិកគីពណ៌ខៀវ ស្បែកជើងបំពង់កៅស៊ូ កវែងពណ៌ខ្មៅ។

៣- ពេទ្យយោធា

-ឯកសណ្ឋានពណ៌ស អាវដៃខ្លី កបើក ហោប៉ៅ៣ (មួយនៅលើខាងឆ្វេងគ្មានគម្របនិងពីរនៅខាងក្រោមធំគ្មានគម្រប) កាត់ស្រុងវែងដល់ជង្គង់

-ខោជើងវែងពណ៌ស ចង្កេះរឹត មានហោប៉ៅក្រោយមួយគ្មានគម្រប។

**មាត្រា ៩.-**

ត្រូវបានរៀបចំស្លាកសញ្ញាកងទ័ពជើងគោកដូចខាងក្រោម៖

១- សញ្ញាលើហោប៉ៅអាវស្តាំ

១.១- សញ្ញាក្រសួងការពារជាតិ

រូបសញ្ញារបស់ក្រសួងការពារជាតិ ត្រូវតំណាងដោយរង្វង់មូល នៅកណ្តាលរង្វង់មូលមានរូបហនុមានទ្រង់គ្រឿង ផ្នែកខាងក្រោមរង្វង់មូលមានចារឹកអក្សរថា **ក្រសួងការពារជាតិ** លើរង្វង់មូលមានម្កុដ លើម្កុដមានពន្លឺឆព្វណ្ណរង្សី ខាងក្រោមរង្វង់មូលទ្រដោយយុថ្កាមានសញ្ញាស្លាបសន្ទឹងសងខាងរង្វង់ និងអមដោយកួរស្រូវព័ទ្ធជុំវិញរង្វង់។

-ពន្លឺឆព្វណ្ណរង្សីតំណាងឲ្យទសពិធរាជធម៌នៃអង្គព្រះមហាក្សត្រ

-រូបម្កុដទ្រង់គ្រឿងតំណាងឲ្យជាតិ សាសនា ព្រះមហាក្សត្រ

-ក្បាច់រំយោលតំណាងឲ្យការរក្សានូវប្រពៃណីនិងខឿនវប្បធម៌ជាតិ

-ស្លាករង្វង់ពណ៌ក្រហមភ្ជាប់ និងរំយោលសងខាងបញ្ជាក់ឲ្យឈ្មោះស្ថាប័នរបស់ក្រសួងការពារជាតិ

-រូបហនុមានទ្រង់គ្រឿង ដៃស្តាំចង្អុលឆ្ពោះត្រង់ទៅមុខ ដៃឆ្វេងកាន់ព្រះខ័នសម្តែងឫទ្ធិ តំណាងឲ្យកងយោធពលខេមរភូមិន្ទជាមេទ័ព និងពលសេនាទ័ពដ៏មានឫទ្ធិ មានទឹកចិត្តភក្តីភាពចំពោះមាតុភូមិការពារជាតិ សាសនា និងព្រះមហាក្សត្រ

-រូបសញ្ញាស្លាបសន្ទឹងសងខាងតំណាងឲ្យកងទ័ពជើងអាកាស និងយុថ្កាតំណាងឲ្យកងទ័ពជើងទឹក ដែលប្រសូតចេញពីប្រជាជនហ៊ានធ្វើពលិកម្មពុះពារជម្នះគ្រប់ឧបសគ្គតូចធំ មានឆន្ទៈមោះមុតដើម្បីការពារខឿនឯករាជ្យជាតិ អធិបតេយ្យភាព និងបូរណភាពទឹកដី ដែនគោក ដែនទឹក ដែនកោះ និងដែនអាកាស រក្សាឲ្យភាពសុខដុមរមនារបស់ប្រជាពលរដ្ឋក្នុងព្រះរាជាណាចក្រកម្ពុជាទាំងមូល

-កួរស្រូវអមសងខាងព័ទ្ធជារង្វង់ បញ្ជាក់ការរួមចំណែក ការបង្កបង្កើនផលក្នុងកិច្ចអភិវឌ្ឍប្រទេសជាតិ មានស្រូវជាដំណាំកសិកម្មដ៏សំខាន់ដែលកងទ័ពយកចិត្តទុកដាក់បំផុតស្របនឹងពាក្យស្លោកថែងថា"ធ្វើស្រែនឹងទឹក ធ្វើសឹកនឹងបាយ"។

រូបសញ្ញានេះមានកម្ពស់ ៨ស.ម បណ្តោយ ៥.៥ស.ម ផលិតពីលោហធាតុ។

១.២- សញ្ញាអគ្គបញ្ជាការដ្ឋាន មានពីរប្រភេទ៖

១.២.១- មានរាងពងក្រពើគ្មានហ្វុងនៅពីក្រោយមានកម្ពស់ ៨៥ម.ម បណ្តោយ ៨៧ម.ម នៅជុំវិញមានរចនាលម្អដោយកួរស្រូវពីរ កោងរាងស្វែងក្របីដែលតំណាងឲ្យប្រជារាស្ត្រ។ នៅចំកណ្តាលមានផ្កាយពណ៌មាសនិងខៀវ មានជ្រុងប្រាំបីដែលតំណាងឲ្យឫទ្ធិបារមីទិសទាំងប្រាំបី។ នៅចំកណ្តាលផ្កាយមានផ្តិប្រសព្វដោយរូបលំពែងត្រីសូលក្រោមរូបម្កុដរាជ្យដែលមានកាំរស្មីប្រាំពីរ ស្លាបសត្វហង្ស និងយុថ្កាពណ៌មាសដែលតំណាងឲ្យកងទ័ពទាំងបីប្រភេទ។រូបសញ្ញានេះផលិតពីលោហធាតុ។

១.២.២- មានរាងជាខែល មានហ្វុងពណ៌ទង់ជាតិបញ្ចូិត មានកម្ពស់១០០ម.ម និងទទឹង៨០ម.ម។

នៅលើផ្ទៃខែលមានរាងដូចសញ្ញាអគ្គបញ្ជាការដ្ឋានទីមួយ មានអក្សរ **ខ.ភ.ម** នៅពីលើរូប និងអក្សរ **អគ្គបញ្ជាការ** នៅពីក្រោមរូប។ សញ្ញានេះប៉ាក់ ឬបោះពុម្ពនៅលើក្រណាត់។

១.៣- សញ្ញាបញ្ជាការដ្ឋានកងទ័ពជើងគោក មានពីរប្រភេទ៖

១.៣.១- មានរាងពងក្រពើពណ៌ទឹកមាស ពណ៌ស មានកម្ពស់ ៨៨ម.ម បណ្តោយ ៥០ម.ម។ នៅខាងក្រោមចំកណ្តាលមានក្បាច់ផ្កាចន្ទន៍ និងមានរូបកួរស្រូវព័ទ្ធជុំវិញជារង្វង់ស្វែងក្របី។ នៅចំកណ្តាលមានទង់ជាតិដែលមានរាងជាខែល និងមានរូបប្រាសាទអង្គរវត្ត។ រូបម្កុដរាជ្យមានកាំរស្មីប្រាំពីរពីលើរូបលំពែងត្រីសូលពណ៌មាស។ ដាវនិងកាំភ្លើងពណ៌មាសដាក់ខ្វែងគ្នាតំណាងឲ្យកងទ័ពជើងគោក។ រូបសញ្ញានេះផលិតពីលោហធាតុ។

១.៣.២- មានរាងពងក្រពើពណ៌ខៀវខ្ចី មានកម្ពស់ ៣៨ម.ម ទទឹង ១៥ម.ម។ នៅចំកណ្តាលមានរូបសញ្ញាដូចកងទ័ពជើងគោកប្រភេទទីមួយ។ សញ្ញានេះប៉ាក់ ឬបោះពុម្ពលើក្រណាត់។

២- សញ្ញាលើ កអាវ

២-១ សញ្ញាកងឯកភាពថ្មើរជើង

រូបភាព: កាំភ្លើងពីសម័យដើមពីរខ្វែងគ្នា រាងសញ្ញាលេខគុណ កាំភ្លើងខាងស្តាំខ្វែងលើកាំភ្លើងខាងឆ្វេង។

ខ្នាត: ប្រវែងកាំភ្លើងនីមួយៗ ៣៥ម.ម ស្មុំយកាំភ្លើងនីមួយៗ ប្រវែង៥ម.ម ចុងកាំភ្លើង ០.៥ម.ម ចំណុចខ្វែងគ្នាចំពាក់កណ្តាលមុមខាងលើ១២៥អង្សារ មុមចំហៀង៥៥អង្សារ។

សញ្ញានេះផលិតពីលោហធាតុពណ៌មាស កម្រាស់១.៥ម.ម និងផលិតពីក្រណាត់ពណ៌ខ្មៅមានប៉ាក់រូបដូចខាងលើពីអំបោះពណ៌មាសដេរភ្ជាប់ កអាវខាងស្តាំ។

២-២ សញ្ញាកងចលនទូបត្ថម្ភ និងសម្ភារ

រូបភាព: មានរូបក្អមនៅខាងលើមានអណ្តាតភ្លើង ក្អមមានគូររង្វង់រាងពងក្រពើ ផលិតពីលោហធាតុពណ៌មាស កម្រាស់១.៥ម.ម។

ខ្នាត: ក្អមមានរាងជារង្វង់បន្ទាត់ផ្ចិត១៥ម.ម មាត់ក្អម៨ម.ម កម្ពស់កក្អម១ម.ម អណ្តាតភ្លើងមាន៤ កម្ពស់អណ្តាតទីមួយ ១៨ម.ម ទីពីរ ២៦ម.ម ទីបី ១៤ម.ម ទីបួន ១២ម.ម អណ្តាតភ្លើងនីមួយៗ មានទទឹង ២ម.ម ស្រួចចុងរាងជាអណ្តាតភ្លើង។

សញ្ញានេះផលិតពីលោហធាតុពណ៌មាស កម្រាស់១.៥ម.ម និងផលិតពីក្រណាត់ពណ៌ខ្មៅមានប៉ាក់រូបដូចខាងលើពីអំបោះពណ៌មាសដេរភ្ជាប់ កអាវខាងស្តាំ។

២-៣ សញ្ញាកងឯកភាពសុខាភិបាល

រូបភាព: មានរូបសញ្ញាលេខបូក នៅសញ្ញាលេខបូកត្រង់ទៅលើមានសត្វពស់រុំនៅពីលើផ្ចិតពីលោហធាតុ សញ្ញាលេខបូកពណ៌ក្រហម ពស់ពណ៌ប្រាក់។

ខ្នាត: សញ្ញាលេខបូកនីមួយៗប្រវែង២៨ម.ម ទទឹង៨ម.ម នៅលើសញ្ញាលេខបូកត្រង់ទៅលើមានផ្នតបណ្តោយប្រវែង៦ម.ម មានសត្វពស់រុំបីជាន់ ក្បាលពស់ដាក់ពីលើកន្ទុយពស់ចុះមកក្រោម២ម.ម ទទឹងពស់ ២ម.ម ។

សញ្ញានេះផលិតពីលោហធាតុពណ៌មាស កម្រាស់១.៥ម.ម និងផលិតពីក្រណាត់ពណ៌ខ្មៅមានប៉ាក់រូបដូចខាងលើពីអំបោះពណ៌មាសដេរភ្ជាប់ កអាវខាងស្តាំ។

២-៤ សញ្ញាកងឯកភាពភូមិសាស្ត្រយោធា

រូបភាព: មានរូបផែនទីព្រះរាជាណាចក្រកម្ពុជាពណ៌មាស ក្នុងនោះមានទន្លេសាប ទន្លេមេគង្គ នៅលើផែនទីមានរូបដែកឈានបញ្ឈរពណ៌ប្រាក់ផលិតពីលោហធាតុ។

ខ្នាត: ទំហំផែនទីមានប្រវែង ៣០ម.ម កម្ពស់ ២៥ម.ម កម្ពស់ដែកឈាន ៣០ម.ម មុមរបស់ចុងដែកឈានបើកចេញពីគ្នា ៥០អង្សារ ចុងដែកឈាននីមួយៗ ២០ម.ម គល់ដែកឈានខាងលើលៀនហួសផែនទី ៥ម.ម ចុងខាងក្រោមលៀនហួសផែនទី ២ម.ម ។

សញ្ញានេះផលិតពីលោហធាតុពណ៌មាស កម្រាស់១.៥ម.ម និងផលិតពីក្រណាត់ពណ៌ខ្មៅមានប៉ាក់រូបដូចខាងលើពីអំបោះពណ៌មាសដេរភ្ជាប់ កអាវខាងស្តាំ។

២-៥ សញ្ញាកងកាំភ្លើងធំ និងការពារដែនអាកាស

រូបភាព: មានកាំជ្រួចមួយបញ្ឈរត្រង់ទៅលើ ហើយមានកាណុងកាំភ្លើងធំពីសម័យដើមពីរខ្វែងគ្នាដាក់ពីលើរូបកាំជ្រួច កាណុងខាងឆ្វេងខ្វែងលើខាងស្តាំ។

ខ្នាត: កម្ពស់កាំជ្រួច ៣៥ម.ម កាណុងកាំភ្លើងធំនីមួយៗប្រវែង ៣៥ម.ម មុមកាណុងកាំភ្លើងធំខ្វែងគ្នាទាំងលើទាំងក្រោម ១១០អង្សារ មុមចំហៀង ៧០អង្សារ ។

សញ្ញានេះផលិតពីលោហធាតុពណ៌មាស កម្រាស់១.៥ម.ម និងផលិតពីក្រណាត់ពណ៌ខ្មៅមានប៉ាក់រូបដូចខាងលើពីអំបោះពណ៌មាសដេរភ្ជាប់កអាវខាងស្តាំ។

២-៦ សញ្ញាកងរថក្រោះ-រថពាសដែក

រូបភាព: រូបដាវពីរខ្វែងគ្នា នៅចំកណ្តាលមានរូបរថក្រោះមើលពីមុខ និងក្រចកសេះផលិតពីលោហធាតុពណ៌មាស កម្រាស់ ១.៥ម.ម។

ខ្នាត: ដាវនីមួយៗ ប្រវែង៥២ម.ម (ក្នុងនោះដងដាវ៨ម.ម) ទទឹងរថក្រោះ ២០ម.ម កម្ពស់ទាំងកាណុង ១៥ម.ម កម្ពស់ក្រចកសេះ ១៧ម.ម ចុងក្រចកសេះខាងលើពីមួយទៅមួយមាន ៩ម.ម លើក្រចកសេះមានស្នាមបោះដែកគោលចំនួនប្រាំកន្លែង។

សញ្ញានេះផលិតពីលោហធាតុពណ៌មាស កម្រាស់១.៥ម.ម និងផលិតពីក្រណាត់ពណ៌ខ្មៅមានប៉ាក់រូបដូចខាងលើពីអំបោះពណ៌មាសដេរភ្ជាប់កអាវខាងស្តាំ។

២-៧ សញ្ញាកងឯកភាពបញ្ជូនសារ

រូបភាព: រូបកងចក្រមានស្លាបខាងក្រៅចំនួន១៦ នៅលើរូបកងចក្រមានរូបសញ្ញារលកធាតុអាកាសមុខឡើងទៅលើ ចុងងាកមកស្តាំ២៥អង្សារ។

ខ្នាត: បន្ទាត់ផ្ចិតខាងក្រៅ ២៥ម.ម រង្វង់ខាងក្នុងទីមួយប្រវែង ១៥ម.ម និងទីពីរប្រវែង១០ម.ម សញ្ញារលកធាតុអាកាសបណ្តោយប្រវែង ២៦ម.ម ទទឹងគល់សញ្ញា ៦ម.ម ។

សញ្ញានេះផលិតពីលោហធាតុពណ៌មាស កម្រាស់១.៥ម.ម និងផលិតពីក្រណាត់ពណ៌ខ្មៅមានប៉ាក់រូបដូចខាងលើពីអំបោះពណ៌មាសដេរភ្ជាប់កអាវខាងស្តាំ។

២-៨ សញ្ញាកងវិស្វកម្ម

រូបភាព: និមិត្តសញ្ញារូបព្រះពិស្ណុការមានព្រះហស្តប្រាំបី កាន់កងចក្រមានកាំប្រាំបួន ឲ្យកត្រីសូលចប ពូថៅ ដង្កាប់ គម្ពីរ ដែកឈាន កែង និងស្លាបព្រាកំបោរបាយអរ គង់នៅលើខឿនអមដោយរចនាប័ទ្មភ្ញីអង្គរខាងស្តាំ និងកូរស្រូវខាងឆ្វេងរាងរង្វង់ស្នែងក្របី ផ្នែកខាងលើព្រះសិរ ព្រះពិស្ណុការមានកាំរស្មីពណ្ណរាយ ១១កាំ។

ខ្នាត: មានរាងពងក្រពើ កម្ពស់៣៥ម.ម ទទឹង២៥ម.ម កម្រាស់១.៥ម.ម ព្រះពិស្ណុការមានកម្ពស់ ២៦ម.ម ទំហំស្មា៦ម.ម ខឿនមានកម្ពស់៨ម.ម បាតក្រោម៩ម.ម បាតលើ៧ម.ម កាំរស្មីពណ្ណរាយ កាំនីមួយៗប្រវែង ៨ម.មនិង៥ម.ម ភ្ជីអង្គរប្រវែង៣០ម.ម ទំហំកណ្តាល ៣ម.ម ភ្ជីក្ងូរស្រូវប្រវែង៣០ម.ម ទំហំកណ្តាល ៣ម.ម ផ្ទៃហ្វុងពណ៌ខ្មៅទំហំ ២៧ម.ម គុណ ៣៧ម.ម ។

សញ្ញានេះផលិតពីលោហធាតុពណ៌មាស កម្រាស់១.៥ម.ម និងផលិតពីក្រណាត់ពណ៌ខ្មៅមានប៉ាក់រូបដូចខាងលើពីអំបោះពណ៌មាសដេរភ្ជាប់កអាវខាងស្តាំ។

២-៩ សញ្ញាកងឯកភាពសាលា និងហ្វឹកហ្វឺន

រូបភាព: មានរូបព្រះខ័នខ្វែងជាមួយស្លាបសត្វមួយពណ៌មាស នៅកណ្តាលមានសៀវភៅមួយបើកពណ៌ប្រាក់។

ខ្នាត: ព្រះខ័នប្រវែង ៣៥ម.ម ស្លាបសត្វមួយ ៣៥ម.ម កម្ពស់សៀវភៅ ១០ម.ម បណ្តោយ១៥ម.ម ផ្ចិតកណ្តាលសៀវភៅ ១២ម.ម។

សញ្ញានេះផលិតពីលោហធាតុពណ៌មាស កម្រាស់១.៥ម.ម និងផលិតពីក្រណាត់ពណ៌ខ្មៅមានប៉ាក់រូបដូចខាងលើពីអំបោះពណ៌ មាសដេរភ្ជាប់កអាវខាងស្តាំ។

២-១០ សញ្ញាកងឯកភាពគុលាការយោធា

រូបភាព: រូបក្បាច់ចម្លាក់អង្គរព័ទ្ធជុំវិញរាងស្នែងក្របី ចំកណ្តាលជើងពានជញ្ជីងនិងសន្លឹកសៀវភៅច្បាប់។

ខ្នាត: អង្កត់ផ្ចិតរង្វង់ក្បាច់ចម្លាក់អង្គរខាងក្រៅ ២៥ម.ម ខាងក្នុង ២០ម.ម ជើងពាននិងដងជញ្ជីងប្រវែង១៧ម.ម ដងឆ្កាងជញ្ជីង១៣ម.ម សន្លឹកសៀវភៅរៀបរាងកោងពីលើដងកម្ពស់៥ម.ម ជញ្ជីងបន្តោកចុះ ៦ម.ម។

សញ្ញានេះផលិតពីលោហធាតុពណ៌មាស កម្រាស់១.៥ម.ម និងផលិតពីក្រណាត់ពណ៌ខ្មៅមានប៉ាក់រូបដូចខាងលើពីអំបោះពណ៌មាសដេរភ្ជាប់ កអាវខាងស្តាំ។

២-១១ សញ្ញាកងឯកភាពអយ្យការយោធា

រូបភាព: មានរូបជើងពានចំនួនបីថ្នាក់ទ្រជញ្ជីង។

ខ្នាត: កម្ពស់រូបភាព៣០ម.ម បាតជើងពានខាងក្រោម១៦ម.ម បាតជើងពានទីពីរប្រវែង១០ម.ម មាត់ជើងពានទីពីរប្រវែង ២០ម.ម បាតជើងពានទីបីប្រវែង ១១ម.ម មាត់លើប្រវែង ១៥ម.ម បង្គោលជញ្ជីងរាងកោងចុងមានក្បាច់ប្រវែង ១៧ម.ម ជញ្ជីងបន្តោកចុះ ៦ម.ម កម្ពស់ជញ្ជីងទីមួយ និងទីពីរ ប្រវែង ១៥ម.ម ជើងពានទីបី ៦ម.ម។

សញ្ញានេះផលិតពីលោហធាតុពណ៌មាស កម្រាស់១.៥ម.ម និងផលិតពីក្រណាត់ពណ៌ខ្មៅមានប៉ាក់រូបដូចខាងលើពីអំបោះពណ៌មាសដេរភ្ជាប់ កអាវខាងស្តាំ។

២-១២ សញ្ញាត្រៃទ័ព សិល្បៈកងយោធពលខេមរភូមិន្ទ

រូបភាព: មានរូបអក្សរភ្លេងពីសម័យដើម។

ខ្នាត: កម្ពស់រូបភាព ២៦ម.ម បាតក្រោម ១២ម.ម ទទឹងរូបភាពកណ្តាល ២០ម.ម គំនូសកាត់ខាងលើ ១៦ម.ម កម្រាស់ ១.៥ម.ម ។

សញ្ញានេះផលិតពីលោហធាតុពណ៌មាស កម្រាស់១.៥ម.ម និងផលិតពីក្រណាត់ពណ៌ខ្មៅមានប៉ាក់រូបដូចខាងលើពីអំបោះពណ៌មាសដេរភ្ជាប់ កអាវខាងស្តាំ។

២-១៣ ស្លាកសញ្ញាកងឯកភាពបច្ចេកទេស

ស្លាកសញ្ញាបច្ចេកទេសរួមមានពីរប្រភេទគឺ ប្រភេទទីមួយសម្រាប់នាយទាហាន នាយទាហានរង និងពលទាហានជំនាញបច្ចេកទេសនៅក្រសួង និងចំណុះអគ្គបញ្ជាការដ្ឋាន និងប្រភេទទីពីរសម្រាប់នាយទាហាន នាយទាហានរង និងពលទាហាននៅតាមបណ្តាកងឯកភាពចំណុះ។

-សញ្ញាបច្ចេកទេសទីមួយ

រូបភាព: មានរូបដែកឈាន ស្លាបសត្វ នាវា កាំភ្លើងធំនិងសញ្ញាគ្រឿងចក្រផលិតពីលោហធាតុពណ៌មាស។

ខ្នាត: កម្ពស់ដែកឈាន (កម្ពស់រូបភាព) ៣ស.ម ចន្លោះចុងដែកឈានម្ខាងទៅម្ខាង ១.៨ស.ម ចុងស្លាបសត្វម្ខាង២ស.មស្លាបសត្វម្ខាងៗ មានស្លាប៩ជាន់ ហើយស្លាបសត្វដាក់នៅចំកណ្តាលដែកឈាន នៅចន្លោះកណ្តាលស្លាបសត្វមានរូបនាវាធុនតូចបីបញ្ឈរបណ្តោយដែកឈាន ដែលមានមុខស្រួចបណ្តោយ ១ស.ម ទទឹងតួទនាវា ០.៣៥ស.ម នៅផ្នែកខាងក្រោយនាវាមានក្បាច់ចតុកោណកែងបួនជាន់ត្រួតលើគ្នា ផ្នែកខាងមុខនាវាមានដាក់រូបកាំភ្លើងធំ បណ្តោយ០.៣ស.ម នៅខាងក្រោមស្លាបសត្វមានរូបសញ្ញាគ្រឿងចក្រខាងក្រោម ២ស.ម បណ្តោយលើ ១.៥ស.ម ទទឹងសញ្ញាគ្រឿងចក្រ ០.៤០ស.ម ។

-សញ្ញាបច្ចេកទេសទីពីរ

រូបភាព: មានរូបកាំភ្លើងពីសម័យបុរាណខ្វែងជាមួយ (កាំភ្លើងនៅឆ្វេងលើកូនសោខាងស្តាំ) មានរូបសញ្ញាគ្រឿងចក្រដាក់លើកាំភ្លើង និងកូនសោផ្នែកខាងក្រោមផលិតពីលោហធាតុពណ៌មាស។

ខ្នាត: កម្ពស់កាំភ្លើង ៣ស.ម កម្ពស់កូនសោ ២.៥ស.ម មុមខ្វែងគ្នារវាងកាំភ្លើងនិងកូនសោ ១៨អង្សា សញ្ញាគ្រឿងចក្ររាងកោងឡើងលើបណ្តោយខាងក្រោម ២ស.ម បណ្តោយលើ ១.២ស.ម ទទឹងសញ្ញាគ្រឿងចក្រ ០.៤ស.ម ។

សញ្ញានេះផលិតពីលោហធាតុពណ៌មាស កម្រាស់១.៥ម.ម និងផលិតពីក្រណាត់ព៌ណ៌ខ្មៅមានប៉ាក់រូបដូចខាងលើពីអំបោះពណ៌មាសដេរភ្ជាប់កអាវខាងស្តាំ។

២-១៤ ស្លាកសញ្ញាកអាវរបស់កងទ័ពពិសេសឆត្រយោង

រូបភាព: មានរូបកាំភ្លើងពីបុរាណ ពីរដាក់ខ្វែងគ្នា (ខាងឆ្វេងគងលើខាងស្តាំ) និងរូបឆត្រយោងនៅចន្លោះខ្វែងគ្នារវាងកាំភ្លើងទាំងពីរផ្នែកខាងលើ។

ខ្នាត: កម្ពស់កាំភ្លើងមួយ ៣.២ស.ម មុមខ្វែងគ្នារបស់កាំភ្លើង ៨០អង្សា កម្ពស់ឆត្រគិតទាំងខ្សែ ១.៤ស.ម និងខ្សែឆត្រចំនួន៥ (តួឆត្រខាងលើកម្ពស់ ០.៧ស.ម)។

សញ្ញានេះផលិតពីលោហធាតុពណ៌មាស កម្រាស់១.៥ម.ម និងផលិតពីក្រណាត់ពណ៌ខ្មៅមានប៉ាក់រូបដូចខាងលើពីអំបោះពណ៌មាសដេរភ្ជាប់កអាវខាងស្តាំ។

២-១៥ ស្លាកសញ្ញាកងឯកភាពដឹកជញ្ជូនគ្រប់ប្រភេទ

រូបភាព: មានរាងជារង្វង់មូលដែលជានិមិត្តរូបចង្កូតកប៉ាល់ និងចង្កូតរថយន្តដាក់ត្រួតពីលើគ្នា ហើយមានកាំចំនួន៨ពណ៌មាស នៅចំកណ្តាលមានរូបស្លាបសត្វពណ៌ប្រាក់តំណាងឲ្យកងដឹកជញ្ជូនជើងអាកាស។

ខ្នាត: រង្វង់ខាងក្រៅមានអង្កត់ផ្ចិតប្រវែង ២៨ម.ម រង្វង់ខាងក្នុងមានអង្កត់ផ្ចិត ២០ម.ម នៅផ្នែករង្វង់ខាងក្រៅមានធ្វើជាគន្លាក់ដូចសញ្ញាគ្រឿងចក្រ កាំនៃរង្វង់មាន៨ចង្កុលទាំង៨ទិស ស្លាបសត្វខាងក្នុងចំ-កណ្តាលនៃរង្វង់ដាក់គល់ស្លាបមកក្រោម ចុងស្លាបឡើងលើ ស្លាបមានចំនួនពីរជាន់ ស្លាបនីមួយៗមានស្រទាប់ស្លាបចំនួន៦ កម្ពស់រូបភាពស្លាបប្រវែង ១២ម.ម និង ទទឹងប្រវែង ៨ម.ម។ ស្លាកសញ្ញានេះសម្រាប់

កងឯកភាពដឹកជញ្ជូនគ្រប់ប្រភេទដូចជាដឹកជញ្ជូនជើងគោក ជើងទឹក និងជើងអាកាស។

សញ្ញានេះផលិតពីលោហធាតុពណ៌មាស កម្រាស់១.៥ម.ម និងផលិតពីក្រណាត់ពណ៌ខ្មៅមានប៉ាក់រូបដូចខាងលើពីអំបោះពណ៌មាសដេរភ្ជាប់ កអាវខាងស្តាំ។

រូបភាពឯកសណ្ឋានគ្រប់ប្រភេទនិងស្លាកសញ្ញានានារបស់កងទ័ពជើងគោកមានគំរូដូចក្នុងឧបសម្ព័ន្ធទី១នៃអនុក្រឹត្យនេះ។

## ជំពូកទី៣
## ឯកសណ្ឋាននិងស្លាកសញ្ញាកងទ័ពជើងទឹក

**មាត្រា ១០.-**

ត្រូវបានរៀបចំឯកសណ្ឋានធំលេខ១ សម្រាប់កងទ័ពជើងទឹកដែលមានរូបភាព និងម៉ូដដូចខាងក្រោម៖

១. ឯកសណ្ឋានថ្នាក់ឧត្តមនាវី

-អាវកុដពណ៌ស កត្រង់ ខោជើងវែងពណ៌ស មួកកាស្កេតពណ៌ស ជើងមួកពណ៌ក្រហមកាត់ម៉ូដដូចថ្នាក់ឧត្តមសេនីយ៍កងទ័ពជើងគោក

-ស្បែកជើងស្បែក កខ្លីពណ៌សចងខ្សែ ស្រោមជើងពណ៌សនិងស្រោមដៃពណ៌ស ខ្សែក្រវ៉ាត់ពណ៌សក្បាលខ្សែក្រវ៉ាត់ធ្វើពីលោហធាតុលាតពណ៌មាស។

ចំពោះនារីអាវមានគំរូដូចបុរសតែកាត់តាមរាងដងខ្លួន និងសំពត់ហ្ស៊ីបក្រោមជង្គង់ពណ៌សមានឆ្នូតក្រហមសងខាងដូចគ្នា។

២. ឯកសណ្ឋានថ្នាក់វរនាវី

-អាវកុដពណ៌ស កត្រង់ ខោជើងវែងពណ៌ស មួកកាស្កេតពណ៌ស ជើងមួកពណ៌ក្រហមកាត់ម៉ូដដូចថ្នាក់វរសេនីយ៍កងទ័ពជើងគោក

-ស្បែកជើងស្បែក កខ្លីពណ៌សចងខ្សែ ស្រោមជើងពណ៌សនិងស្រោមដៃពណ៌ស ខ្សែក្រវ៉ាត់ពណ៌សក្បាលខ្សែក្រវ៉ាត់ពណ៌មាស។

ចំពោះនារីអាវមានគំរូដូចបុរសតែកាត់តាមរាងដងខ្លួន និងសំពត់ហ្ស៊ីបក្រោមជង្គង់ពណ៌សមានឆ្នូតក្រហមសងខាងដូចគ្នា។

៣. ឯកសណ្ឋានថ្នាក់អនុនាវី

-អាវកុដពណ៌ស កត្រង់ ខោជើងវែងពណ៌ស មួកកាស្កេតពណ៌ស ជើងមួកពណ៌ក្រហមកាត់ម៉ូដដូចថ្នាក់អនុសេនីយ៍កងទ័ពជើងគោក

-ស្បែកជើងស្បែក កខ្លីពណ៌សចងខ្សែ ស្រោមជើងពណ៌សនិងស្រោមដៃពណ៌ស ខ្សែក្រវ៉ាត់ពណ៌សក្បាលខ្សែក្រវ៉ាត់ពណ៌មាស។

ចំពោះនារី អាវមានគំរូដូចបុរសតែកាត់រាងតាមដងខ្លួននិងសំពត់ហ្ស៊ីបក្រោមជង្គង់ពណ៌សមានឆ្នូតក្រហមសងខាងដូចគ្នា។

**មាត្រា ១១.-**

ត្រូវបានរៀបចំឯកសណ្ឋានធំលេខ២ សម្រាប់កងទ័ពជើងទឹកដែលមានរូបភាព និងម៉ូដដូចខាងក្រោម៖

១. ឯកសណ្ឋានថ្នាក់ឧត្តមនាវី

អាវដៃវែង ខោជើងវែងពណ៌សកាត់ម៉ូដ ដូចថ្នាក់ឧត្តមសេនីយ៍កងទ័ពជើងគោក អាវសឺមី មួក ស្រោមដៃ ខ្សែក្រវ៉ាត់និងស្បែកជើងស្បែក កខ្លីពណ៌សចងខ្សែ ក្រវ៉ាត់កពណ៌ខ្មៅ ជើងមួកពណ៌ខ្មៅនិងក្បាលខ្សែក្រវ៉ាត់លាតពណ៌មាស។

ចំពោះនារី អាវមានគំរូដូចបុរសតែកាត់រាងតាមដងខ្លួននិងសំពត់ហ្ស៊ីបក្រោមជង្គង់ពណ៌ស។

ត្រូវបានបន្ថែមឯកសណ្ឋានពណ៌ខ្មៅមួយសម្រាប់ទៀតដែលមានម៉ូដអាវលំនាំវ៉ាវី កបើកគ្មានផែកខ្នង គ្មានប៉ូលស្មាមានហោប៉ៅចំនួន៣ (ហោប៉ៅលើក្រោមដេរបង្កប់) ឡេវពីរជួរដាក់ខាងមុខបួនម្ខាងមានរូបព្រះសង្ហារពណ៌មាសមានអង្កត់ផ្ចិត២៥ម.ម។ នៅចុងដៃអាវមានដេរសញ្ញាសក្តិប្រវែង៦ស.មឃ្លាតពីចុងដៃអាវឡើងមកលើតាមឋានន្តរសក្តិ។ អាវសឺមីពណ៌ស ក្រវ៉ាត់កពណ៌ខ្មៅ ស្បែកជើងស្បែក កខ្លីពណ៌ខ្មៅចងខ្សែ ស្រោមជើងពណ៌ខ្មៅ។

ចំពោះនារីអាវមានគំរូដូចបុរសតែកាត់រាងតាមដងខ្លួន និងសំពត់ហ្ស៊ីបក្រោមជង្គង់។

ថ្នាក់នាយឧត្តមនាវី ដេររំលេចខ្សែកាត់ឆ្នូតធំពណ៌មាសជុំវិញដៃអាវមានទំហំ៤.៥ស.ម ឃ្លាតពីចុងដៃអាវ៦ស.ម មានដេររំលេចខ្សែកាត់ឆ្នូតតូចពណ៌មាសចំនួនបីខ្សែ (ខ្សែនីមួយៗមានទំហំ០.៨ស.ម) ឃ្លាតពីខ្សែកាត់ធំ០.៥ស.ម ដេញមកលើមានចន្លោះស្មើៗគ្នានិងមានដេររំលេចផ្កាយមួយគ្រាប់នៅពីលើ (ទំហំផ្កាយស្មើនឹងគ្រាប់ផ្កាយសក្តិលើស្មា) ឃ្លាតពីខ្សែកាត់តូចពណ៌មាសដេញមកលើ០.២ស.ម។

ចំពោះថ្នាក់ឧត្តមនាវីឯកខុសត្រង់ខ្សែកាត់ឆ្នូតតូចពណ៌មាសមានតែ២ ឧត្តមនាវីទោមានតែ១ និងឧត្តមនាវីត្រីគ្មានខ្សែកាត់ឆ្នូតតូច។ អាវសឺមីពណ៌ស ក្រវ៉ាត់កពណ៌ខ្មៅ ស្បែកជើងស្បែក កខ្លីពណ៌ខ្មៅចងខ្សែ ស្រោមជើងពណ៌ខ្មៅ ខ្សែក្រវ៉ាត់ពណ៌ខ្មៅ ក្បាលខ្សែក្រវ៉ាត់ពណ៌មាស។

២. ឯកសណ្ឋានថ្នាក់វរនាវី

អាវវ៉ាវី ខោជើងវែងពណ៌ស កាត់ម៉ូដដូចថ្នាក់វរសេនីយ៍កងទ័ពជើងគោក អាវសឺមី មួក ស្រោមដៃ ខ្សែក្រវ៉ាត់និងស្បែកជើងស្បែក កខ្លីពណ៌សចងខ្សែ ក្រវ៉ាត់កពណ៌ខ្មៅ ជើងមួកពណ៌ខ្មៅនិងក្បាលខ្សែ ក្រវ៉ាត់លាតពណ៌មាស។

ត្រូវបានបន្ថែមឯកសណ្ឋានពណ៌ខ្មៅមួយសម្រាប់ទៀតដែលមានម៉ូដ ដូចថ្នាក់ឧត្តមនាវី នៅចុងដៃអាវមានដេរសញ្ញាសក្តិប្រវែង៦ស.ម ឃ្លាតពីចុងដៃអាវឡើងមកលើតាមឋានន្តរសក្តិ។

ថ្នាក់វរនាវីឯក ដេររំលេចខ្សែកាត់ឆ្នូតតូចពណ៌មាសជុំវិញដៃអាវចំនួន៤ខ្សែឃ្លាតពីចុងដៃអាវនិងចន្លោះពីមួយទៅមួយដូចថ្នាក់ឧត្តមនាវីដែរ។ ថ្នាក់វរនាវីទោ រំលេចខ្សែកាត់ឆ្នូតតូចពណ៌មាសជុំវិញដៃអាវចំនួន៣ខ្សែ។ ថ្នាក់វរនាវីត្រី រំលេចខ្សែកាត់ឆ្នូតតូចពណ៌មាសជុំវិញដៃអាវចំនួន២ខ្សែនិងមានខ្សែកាត់ឆ្នូតតូចបំផុត(ទំហំ០.៨ស.ម)មួយទៀតនៅចំកណ្តាល។ អាវសឺមីពណ៌ស ក្រវ៉ាត់កពណ៌ខ្មៅ ស្បែកជើងស្បែក កខ្លីពណ៌ខ្មៅចងខ្សែ ស្រោមជើងពណ៌ខ្មៅ ខ្សែក្រវ៉ាត់ពណ៌ខ្មៅ ក្បាលខ្សែក្រវ៉ាត់ពណ៌មាស។

៣. ឯកសណ្ឋានថ្នាក់អនុនាវី

អាវវ៉ាវី ខោជើងវែងពណ៌សកាត់ម៉ូដដូចថ្នាក់អនុសេនីយ៍កងទ័ពជើងគោក អាវសឺមី មួកស្រោមដៃ ខ្សែក្រវ៉ាត់និងស្បែកជើងស្បែក កខ្លីពណ៌សចងខ្សែ ក្រវ៉ាត់កពណ៌ខ្មៅ ជើងមួកពណ៌ខ្មៅនិងក្បាលខ្សែក្រវ៉ាត់លាតពណ៌មាស។

មានបន្ថែមឯកសណ្ឋានពណ៌ខ្មៅដូចថ្នាក់វរនាវីដែរ តែខុសគ្នាត្រង់ចុងដៃអាវ ថ្នាក់អនុនាវីឯក ដេររំលេចខ្សែកាត់ឆ្នូតតូចពណ៌មាសជុំវិញដៃអាវចំនួន២ខ្សែ។ ថ្នាក់អនុនាវីទោ រំលេចខ្សែកាត់ឆ្នូតតូចពណ៌

មាសជុំវិញដៃអាវចំនួនមួយខ្សែនិងមានខ្សែកាត់ឆ្នូតតូចប់ផុតមួយខ្សែទៀតនៅពីលើ។ ថ្នាក់អនុនាវីត្រី រំលេចខ្សែកាត់ឆ្នូតតូចពណ៌មាសជុំវិញដៃអាវចំនួនមួយខ្សែ។ អាវសឺមីពណ៌ស ក្រវ៉ាត់កពណ៌ខ្មៅ ស្បែកជើងស្បែក កខ្លីពណ៌ខ្មៅចងខ្សែ ស្រោមជើងពណ៌ខ្មៅ ខ្សែក្រវ៉ាត់ពណ៌ខ្មៅ ក្បាលខ្សែក្រវ៉ាត់ធ្វើពីលោហធាតុលាតពណ៌មាស។

ឯកសណ្ឋានពណ៌ខ្មៅត្រូវបានបន្ថែមចំពោះតែនាយនាវីប៉ុណ្ណោះ។

សម្រាប់នាយនាវីរងនិងពលនាវី នៅពេលបំពេញបេសកកម្មក្រៅប្រទេសឬក្នុងពិធីការជាតិធំៗ អាចមានឯកសណ្ឋានធំលេខ២ដែរ ហើយឯកសណ្ឋាននោះដូចគ្នាថ្នាក់អនុនាវី តែមួកកាស្កេតគ្មានក្បាច់ភ្ញីទេសឬឆ្នូតអ្វីទាំងអស់។

**មាត្រា ១២.-**

ត្រូវបានរៀបចំឯកសណ្ឋានលេខ៣ សម្រាប់កងទ័ពជើងទឹកដែលមានរូបភាព និងម៉ូដដូចខាងក្រោម៖

១. ឯកសណ្ឋានថ្នាក់ឧត្តមនាវី

-អាវពណ៌ស ខោពណ៌ស កាត់ម៉ូដដូចថ្នាក់ឧត្តមសេនីយ៍កងទ័ពជើងគោក

-អាវយឺតក្នុងដៃខ្លីពណ៌ស

-មួកកាស្កេតពណ៌ស ជើងមួកពណ៌ខ្មៅកាត់ម៉ូតដូចថ្នាក់ឧត្តមសេនីយ៍កងទ័ពជើងគោក

-ខ្សែក្រវ៉ាត់ពណ៌ស ក្បាលខ្សែក្រវ៉ាត់ធ្វើពីលោហធាតុលាតពណ៌មាស ស្បែកជើងស្បែកកខ្លីពណ៌សចងខ្សែ និងស្រោមជើងពណ៌ស។

២. ឯកសណ្ឋានថ្នាក់វរនាវី

-អាវពណ៌ស ខោពណ៌ស កាត់ម៉ូដដូចថ្នាក់វរសេនីយ៍កងទ័ពជើងគោក

-អាវយឺតក្នុងដៃខ្លីពណ៌ស

-មួកកាស្កេតពណ៌ស ជើងមួកពណ៌ខ្មៅកាត់ម៉ូតដូចថ្នាក់វរសេនីយ៍កងទ័ពជើងគោក

-ខ្សែក្រវ៉ាត់ពណ៌ស ក្បាលខ្សែក្រវ៉ាត់ធ្វើពីលោហធាតុលាតពណ៌មាស ស្បែកជើងស្បែកកខ្លីពណ៌សចងខ្សែ និងស្រោមជើងពណ៌ស។

៣. ឯកសណ្ឋានថ្នាក់អនុនាវី

-អាវពណ៌ស ខោពណ៌ស កាត់ម៉ូដដូចថ្នាក់អនុសេនីយ៍កងទ័ពជើងគោក

-អាវយឺតក្នុងដៃខ្លីពណ៌ស

-មួកកាស្កេតពណ៌ស ជើងមួកពណ៌ខ្មៅកាត់ម៉ូតដូចថ្នាក់អនុសេនីយ៍កងទ័ពជើងគោក

-ខ្សែក្រវ៉ាត់ពណ៌ស ក្បាលខ្សែក្រវ៉ាត់ធ្វើពីលោហធាតុលាតពណ៌មាស ស្បែកជើងស្បែក កខ្លីពណ៌សចងខ្សែ និងស្រោមជើងពណ៌ស។

ចំពោះនារី អាវមានគំរូដូចបុរសតែកាត់តាមរាងដងខ្លួននិងសំពត់ហ្ស៊ីបក្រោមជង្គង់ពណ៌ស។

សម្រាប់នាយនាវីរងនិងពលនាវីនៅពេលបំពេញបេសកកម្មក្រៅប្រទេស ឬក្នុងពិធីការជាតិធំៗអាចមានឯកសណ្ឋានលេខ៣ដែរ ហើយឯកសណ្ឋាននោះដូចគ្នាថ្នាក់អនុនាវី តែមួកកាស្កេតគ្មានក្បាច់ភ្ញីទេសឬឆ្នូតអ្វីទាំងអស់។

**មាត្រា ១៣.-**

ត្រូវបានរៀបចំឯកសណ្ឋានលេខ៤ សម្រាប់កងទ័ពជើងទឹកដែលមានរូបភាព និងម៉ូដដូចខាង

ក្រោម៖

១. ឯកសណ្ឋានថ្នាក់ឧត្តមនាវី

-អាវដៃខ្លីពណ៌ស កខុប មានប៉ូលស្មាទាំងសងខាងកាត់ស្រុងវែងដាក់ក្នុងខោ មានហោប៉ៅពីរដេរបង្កប់ ចំកណ្ដាលដេរបត់ផ្ដត់មួយមានគម្របរាងស្លឹកពោធិ ឡេវធម្មតាពណ៌ស

-ខោជើងវែងពណ៌ស កាត់ម៉ូដដូចឯកសណ្ឋានលេខ៣

-មួកបេរ៉េពណ៌ទឹកសមុទ្រមានប៉ាក់រូបព្រះសង្ហារពណ៌មាស

-ខ្សែក្រវ៉ាត់ពណ៌ស ក្បាលខ្សែក្រវ៉ាត់ធ្វើពីលោហធាតុលាតពណ៌មាស ស្បែកជើងស្បែកកខ្លីពណ៌សចងខ្សែនិងស្រោមជើងពណ៌ស។

២. ឯកសណ្ឋានថ្នាក់វរនាវី ដូចឯកសណ្ឋានថ្នាក់ឧត្តមនាវី។

៣. ឯកសណ្ឋានថ្នាក់អនុនាវី ដូចឯកសណ្ឋានថ្នាក់ឧត្តមនាវី។

ចំពោះនារីអាវដូចបុរសតែកាត់តាមរាងដងខ្លួន ខោជើងវែងពណ៌ស ឬសំពត់ហ្ស៊ីបពណ៌សក្រោមជង្គង់។

៤. ឯកសណ្ឋានថ្នាក់នាយនាវីរង និងពលនាវី

-អាវការងារដៃវែង ពណ៌ស កអាវទម្លាក់មកក្រោមរាងជាកន្សែងវែង ប្រវែង២៥ស.ម ជុំវិញកអាវមានឆ្នូត៣ពណ៌ខៀវ ឆ្នូតនីមួយៗមានទំហំ៨ម.ម

-ខោជើងវែងពណ៌ស ស្បែកជើងស្បែក កខ្លីពណ៌សចងខ្សែ ស្រោមជើងពណ៌ស ខ្សែក្រវ៉ាត់ពណ៌សក្បាលខ្សែក្រវ៉ាត់ធ្វើពីលោហធាតុលាតពណ៌មាស

-មួកម៉ាតឺឡូពណ៌ស ជើងមួកពណ៌ខៀវ លើជើងមួកមានសរសេរអក្សរពណ៌សថា **កងទ័ពជើងទឹក** កំពស់អក្សរ១៥ម.ម។ ជើងមួកខាងក្រោយឆែក មានខ្សែពីរសម្រាប់ចងនៅកន្ទុយខ្សែមានរាងកន្ទុយត្រី។

**មាត្រា ១៤.-**

ត្រូវបានរៀបចំឯកសណ្ឋានលេខ៥ សម្រាប់កងទ័ពជើងទឹកដែលមានរូបភាព និងម៉ូដដូចខាងក្រោម៖

១. ឯកសណ្ឋានថ្នាក់ឧត្តមនាវី

-ខោអាវប៉ាភ៉ាខ្យាច់ កាត់ម៉ូដដូចប៉ាភ៉ាកងទ័ពជើងគោក

-មួកបេរ៉េពណ៌ទឹកសមុទ្រ ឬមួកហ្សិកកីប៉ាភ៉ាខ្យាច់តាមលំដាប់ថ្នាក់ដូចកងទ័ពជើងគោក ឬមួកដែក

-ស្បែកជើងកវែងប៉ាភ៉ាពណ៌ខ្យាច់ ខ្សែក្រវ៉ាត់តូចពណ៌ខ្យាច់ និងខ្សែសាំងទៀរ៉ុងពណ៌ខ្យាច់។

២. ឯកសណ្ឋានថ្នាក់វរនាវី អនុនាវី នាយនាវីរង និងពលនាវី ដូចឯកសណ្ឋានថ្នាក់ឧត្តមនាវីដែរ។

**មាត្រា ១៥.-**

ត្រូវបានរៀបចំឯកសណ្ឋានបច្ចេកទេសជំនាញសម្រាប់កងទ័ពជើងទឹកដូចខាងក្រោម៖

-ឯកសណ្ឋានពណ៌ខៀវ អាវដៃវែង ក្រវ៉ាត់ចង្កេះ ទំហំ ៦ស.ម ដៃអាវដេររាងបំពង់មានក្រវ៉ាត់ដាក់ឡេវហោប៉ៅពីរដេរយោគ គម្របរាងចតុកោណកែងដេរបង្កប់

-ខោជើងវែងចង្កេះតគ្មានក្លី ហោប៉ៅក្រោយដេរបង្កប់ គម្របរាងស្លឹកពោធិនិងមានហោប៉ៅចំហៀងពីរដេរបង្កប់តាមថ្នេរខោ ឡេវបង្កប់ថ្នេរខុប ពាក់មួកហ្សិកកីពណ៌ខៀវ ស្បែកជើងបំពង់កៅស៊ូ កវែងពណ៌ខ្មៅតែមានបន្ថែមខោខ្លីលើជង្គង់មួយទៀត (ម៉ូដដូចៈខោជើងវែងដែរ)។

**មាត្រា ១៦**.-

ត្រូវបានរៀបចំស្លាកសញ្ញាកងទ័ពជើងទឹកដូចខាងក្រោម៖

១. សញ្ញាលើហោប៉ៅអាវស្ដាំ

មានរាងជាទឹករលកពីរជាន់តំណាងផ្ទៃសមុទ្រមានកម្ពស់ ៨៦ម.ម និងបណ្ដោយ ៧០ម.ម។ នៅចំ-កណ្ដាលទឹករលកមានរូបម្កុដរាជ្យដែលមានការស្មើប្រាំពីរ រូបយុថ្កានិងរូបក្បាលនាគដែលតំណាងឲ្យកងទ័ពជើងទឹក។ រូបសញ្ញានេះផលិតពីលោហធាតុ។

២. សញ្ញាលើ កអាវ

ស្លាកសញ្ញាកងទ័ពជើងទឹកមានរូបភាពនិងខ្នាតដូចខាងក្រោម៖

រូបភាព: រូបយុថ្កាពីរខ្វែងគ្នាចំណុចប្រសព្វជាមុមកែង នៅពាក់កណ្ដាលរំលេចដោយខ្សែពួរពីរព័ទ្ធជុំវិញយុថ្កានីមួយៗ។

ខ្នាត: ទំហំរូបភាពសញ្ញាទទឹង២៩ម.ម កម្ពស់២៦ម.ម។ ប្រវែងយុថ្កានីមួយៗ៣៨ម.ម ទំហំដងយុថ្កាទទឹង២ម.ម រង្វង់កងដងយុថ្កាមានអង្កត់ផ្ចិតខាងក្រៅ៨ម.ម និងអង្កត់ផ្ចិតខាងក្នុង២ម.ម ទំហំខ្សែ២ម.ម ប្រវែងដៃកខ្វែងយុថ្កា១០ម.ម ទំហំ១.៥ម.ម ឃ្លាតពីកងយុថ្កា៣ម.មចុងផ្លែយុថ្កាម្ខាងទៅម្ខាងប្រវែង១៦ម.ម។

សញ្ញានេះផលិតពីលោហធាតុពណ៌មាស កម្រាស់១.៥ម.ម និងផលិតពីក្រណាត់ពណ៌ខ្មៅមានប៉ាក់រូបដូចខាងលើពីអំបោះពណ៌មាសដេរភ្ជាប់កអាវខាងស្ដាំ។

រូបភាពឯកសណ្ឋានគ្រប់ប្រភេទនិងស្លាកសញ្ញានានារបស់កងទ័ពជើងទឹកមានគំរូដូចក្នុងឧបសម្ព័ន្ធទី២នៃអនុក្រឹត្យនេះ។

## ជំពូកទី៤
## ឯកសណ្ឋាននិងស្លាកសញ្ញាកងទ័ពជើងអាកាស

**មាត្រា ១៧**.-

ត្រូវបានរៀបចំឯកសណ្ឋានធំលេខ១ សម្រាប់កងទ័ពជើងអាកាសដែលមានរូបភាព និងម៉ូដដូចខាងក្រោម៖

១. ឯកសណ្ឋានថ្នាក់ឧត្ដមសេនីយ៍

-អាវកុដពណ៌ស ខោពណ៌ខៀវទឹកប៊ិក មួកកាស្កេតពណ៌ខៀវទឹកប៊ិក ជើងមួកពណ៌ក្រហម កាត់ម៉ូដដូចថ្នាក់ឧត្ដមសេនីយ៍កងទ័ពជើងគោក

-ស្បែកជើងស្បែក កខ្លីពណ៌ខ្មៅចងខ្សែ ខ្សែក្រវ៉ាត់ពណ៌ខៀវទឹកប៊ិក ក្បាលខ្សែក្រវ៉ាត់ធ្វើពីលោហធាតុលាតពណ៌មាស និងស្រោមដៃពណ៌ស។

ចំពោះនារី អាវមានគំរូដូចបុរសតែកាត់តាមរាងដងខ្លួន និងសំពត់ហ្ស៊ីបក្រោមជង្គង់ពណ៌ខៀវទឹកប៊ិកមានឆ្នូតក្រហមសងខាងដូចគ្នា។

២. ឯកសណ្ឋានថ្នាក់វរសេនីយ៍

-អាវកុដពណ៌ស ខោពណ៌ខៀវទឹកប៊ិក មួកកាស្កេតពណ៌ខៀវទឹកប៊ិក ជើងមួកពណ៌ក្រហម កាត់ម៉ូដដូចថ្នាក់វរសេនីយ៍កងទ័ពជើងគោក

-ស្បែកជើងស្បែក កខ្លីពណ៌ខ្មៅចងខ្សែ ខ្សែក្រវ៉ាត់ពណ៌ខៀវទឹកប៊ិក ក្បាលខ្សែក្រវ៉ាត់ធ្វើពីលោហធាតុលាតពណ៌មាស និងស្រោមដៃពណ៌ស។

ចំពោះនារី អាវមានគំរូដូចបុរសតែកាត់តាមរាងដងខ្លួន និងសំពត់ហ្ស៊ីបក្រោមជង្គង់ពណ៌ខៀវទឹក

បិក។

៣. ឯកសណ្ឋានថ្នាក់អនុសេនីយ៍

-អាវកុដពណ៌ស ខោពណ៌ខៀវទឹកប៊ិក មួកកាស្កេតពណ៌ខៀវទឹកប៊ិក ជើងមួកពណ៌ក្រហម កាត់ម៉ូដដូចថ្នាក់អនុសេនីយ៍កងទ័ពជើងគោក

-ស្បែកជើងស្បែក កខ្លីពណ៌ខ្មៅចងខ្សែ ខ្សែក្រវ៉ាត់ពណ៌ខៀវទឹកប៊ិក ក្បាលខ្សែក្រវ៉ាត់ធ្វើពីលោហធាតុលាតពណ៌មាស និងស្រោមដៃពណ៌ស។

ចំពោះនារី អាវមានគំរូដូចបុរសតែកាត់តាមរាងដងខ្លួន និងសំពត់ហ្ស៊ីបក្រោមជង្គង់ពណ៌ខៀវទឹកប៊ិក។

**មាត្រា ១៨.-**

ត្រូវបានរៀបចំឯកសណ្ឋានធំលេខ២ សម្រាប់កងទ័ពជើងអាកាសដែលមានរូបភាព និងម៉ូដដូចខាងក្រោម៖

១. ឯកសណ្ឋានថ្នាក់ឧត្តមសេនីយ៍

-អាវដៃវែង ខោជើងវែងពណ៌ខៀវទឹកប៊ិក អាវសឺមីក្នុងពណ៌ផ្ទៃមេឃ ក្រវ៉ាត់កពណ៌ខ្មៅ មួកកាស្កេតពណ៌ខៀវទឹកប៊ិក ជើងមួកពណ៌ក្រហម កាត់ម៉ូដដូចថ្នាក់ឧត្តមសេនីយ៍កងទ័ពជើងគោក

-ស្បែកជើងស្បែក កខ្លីពណ៌ខ្មៅចងខ្សែ ខ្សែក្រវ៉ាត់ពណ៌ខៀវទឹកប៊ិក ក្បាលខ្សែក្រវ៉ាត់ធ្វើពីលោហធាតុលាតពណ៌មាស និងស្រោមដៃពណ៌ស។

ចំពោះនារី អាវមានគំរូដូចបុរសតែកាត់តាមរាងដងខ្លួន និងសំពត់ហ្ស៊ីបក្រោមជង្គង់ពណ៌ខៀវទឹកប៊ិក។

២. ឯកសណ្ឋានថ្នាក់វរសេនីយ៍

-អាវដៃវែង ខោជើងវែងពណ៌ខៀវទឹកប៊ិក អាវសឺមីក្នុងពណ៌ផ្ទៃមេឃ ក្រវ៉ាត់កពណ៌ខ្មៅ មួកកាស្កេតពណ៌ខៀវទឹកប៊ិក ជើងមួកពណ៌ក្រហម កាត់ម៉ូដដូចថ្នាក់វរសេនីយ៍កងទ័ពជើងគោក

-ស្បែកជើងស្បែក កខ្លីពណ៌ខ្មៅចងខ្សែ ខ្សែក្រវ៉ាត់ពណ៌ខៀវទឹកប៊ិក ក្បាលខ្សែក្រវ៉ាត់ធ្វើពីលោហធាតុលាតពណ៌មាស និងស្រោមដៃពណ៌ស។

ចំពោះនារី អាវមានគំរូដូចបុរសតែកាត់តាមរាងដងខ្លួន និងសំពត់ហ្ស៊ីបក្រោមជង្គង់ពណ៌ខៀវទឹកប៊ិក។

៣. ឯកសណ្ឋានថ្នាក់អនុសេនីយ៍

-អាវដៃវែង ខោជើងវែងពណ៌ខៀវទឹកប៊ិក អាវសឺមីក្នុងពណ៌ផ្ទៃមេឃ ក្រវ៉ាត់កពណ៌ខ្មៅ មួកកាស្កេតពណ៌ខៀវទឹកប៊ិក ជើងមួកពណ៌ក្រហមកាត់ម៉ូដដូចថ្នាក់អនុសេនីយ៍កងទ័ពជើងគោក

-ស្បែកជើងស្បែក កខ្លីពណ៌ខ្មៅចងខ្សែ ខ្សែក្រវ៉ាត់ពណ៌ខៀវទឹកប៊ិក ក្បាលខ្សែក្រវ៉ាត់ធ្វើពីលោហធាតុលាតពណ៌មាស និងស្រោមដៃពណ៌ស។

ចំពោះនារី អាវមានគំរូដូចបុរសតែកាត់តាមរាងដងខ្លួន និងសំពត់ហ្ស៊ីបក្រោមជង្គង់ពណ៌ខៀវទឹកប៊ិក។

សម្រាប់នាយទាហានរងនិងពលទាហាននៅពេលបំពេញបេសកកម្ម និងសិក្សាក្រៅប្រទេស ឬក្នុងពិធីការជាតិធំៗ អាចមានឯកសណ្ឋានធំលេខ២ដែរហើយឯកសណ្ឋាននោះដូចគ្នាថ្នាក់អនុសេនីយ៍ តែមួកកាស្កេតនៅហាមមួកគ្មានក្បាច់ភ្ញីទេសឬឆ្នូតអ្វីទាំងអស់។

**មាត្រា ១៩.-**

ត្រូវបានរៀបចំឯកសណ្ឋានលេខ៣ សម្រាប់កងទ័ពជើងអាកាសដែលមានរូបភាព និងម៉ូដដូចខាងក្រោម៖

១. ឯកសណ្ឋានថ្នាក់ឧត្តមសេនីយ៍

-អាវ ខោ មួកកាស្កេតពណ៌ខៀវទឹកប៊ិក កាត់ម៉ូដដូចថ្នាក់ឧត្តមសេនីយ៍កងទ័ពជើងគោក

-អាវយឺតក្នុងដៃខ្លីពណ៌គ្រែអ៊ី

-ស្បែកជើងស្បែក កខ្លីពណ៌ខ្មៅចងខ្សែ ខ្សែក្រវ៉ាត់ខៀវពណ៌ទឹកប៊ិក ក្បាលខ្សែក្រវ៉ាត់ធ្វើពីលោហធាតុលាតពណ៌មាស។

ចំពោះនារី អាវមានគំរូដូចបុរសតែកាត់តាមរាងដងខ្លួន និងសំពត់ហ្ស៊ីបក្រោមជង្គង់ពណ៌ខៀវទឹកប៊ិក។

២. ឯកសណ្ឋានថ្នាក់វរសេនីយ៍

-អាវ ខោ មួកកាស្កេតពណ៌ខៀវទឹកប៊ិក កាត់ម៉ូដដូចថ្នាក់វរសេនីយ៍កងទ័ពជើងគោក

-អាវយឺតក្នុងដៃខ្លីពណ៌គ្រែអ៊ី

-ស្បែកជើងស្បែក កខ្លីពណ៌ខ្មៅចងខ្សែ ខ្សែក្រវ៉ាត់ពណ៌ខៀវទឹកប៊ិក ក្បាលខ្សែក្រវ៉ាត់ធ្វើពីលោហធាតុលាតពណ៌មាស។

ចំពោះនារី អាវមានគំរូដូចបុរសតែកាត់តាមរាងដងខ្លួន និងសំពត់ហ្ស៊ីបក្រោមជង្គង់ពណ៌ខៀវទឹកប៊ិក។

៣. ឯកសណ្ឋានថ្នាក់អនុសេនីយ៍

-អាវ ខោ មួកកាស្កេតពណ៌ខៀវទឹកប៊ិក កាត់ម៉ូដដូចថ្នាក់អនុសេនីយ៍កងទ័ពជើងគោក

-អាវយឺតក្នុងដៃខ្លីពណ៌គ្រែអ៊ី

-ស្បែកជើងស្បែក កខ្លីពណ៌ខ្មៅចងខ្សែ ខ្សែក្រវ៉ាត់ពណ៌ខៀវទឹកប៊ិក ក្បាលខ្សែក្រវ៉ាត់ធ្វើពីលោហធាតុលាតពណ៌មាស។

ចំពោះនារី អាវមានគំរូដូចបុរសតែកាត់តាមរាងដងខ្លួន និងសំពត់ហ្ស៊ីបក្រោមជង្គង់ពណ៌ខៀវទឹកប៊ិក។

សម្រាប់នាយទាហានរង និងពលទាហាននៅពេលបំពេញបេសកកម្មក្រៅប្រទេស ឬក្នុងពិធីការជាតិធំៗ អាចមានឯកសណ្ឋានលេខ៣ដែរ ហើយឯកសណ្ឋាននោះដូចគ្នាថ្នាក់អនុសេនីយ៍តែមួកកាស្កេតនៅហាមមួកគ្មានក្បាច់ភ្ញីទេសឬឆ្នូតអ្វីទាំងអស់។

**មាត្រា ២០.-**

ត្រូវបានរៀបចំឯកសណ្ឋានលេខ៤ សម្រាប់កងទ័ពជើងអាកាសដែលមានរូបភាព និងម៉ូដដូចខាងក្រោម៖

១. ឯកសណ្ឋានថ្នាក់ឧត្តមសេនីយ៍

-អាវដៃវែងពណ៌ផ្ទៃមេឃ ខោពណ៌ខៀវទឹកប៊ិក កាត់ម៉ូដដូចថ្នាក់ឧត្តមសេនីយ៍កងទ័ពជើងគោក

-ស្បែកជើងស្បែក កខ្លីពណ៌ខ្មៅចងខ្សែ ខ្សែក្រវ៉ាត់ពណ៌ខៀវទឹកប៊ិក ក្បាលខ្សែក្រវ៉ាត់ធ្វើពីលោហធាតុលាតពណ៌មាស

-មួកបោណេឬបេរ៉េពណ៌ខៀវទឹកប៊ិក។

ចំពោះនារី អាវមានគំរូដូចបុរសតែកាត់តាមរាងដងខ្លួន ខោជើងវែង ឬសំពត់ហ្សីបក្រោមជង្គង់ពណ៌ខៀវទឹកប៊ិក។

២. ឯកសណ្ឋានថ្នាក់វរសេនីយ៍

-អាវដៃវែងពណ៌ផ្ទៃមេឃ ខោពណ៌ខៀវទឹកប៊ិក កាត់ម៉ូដដូចថ្នាក់វរសេនីយ៍កងទ័ពជើងគោក ស្បែកជើងស្បែក កខ្លីពណ៌ខ្មៅចងខ្សែ ខ្សែក្រវ៉ាត់ពណ៌ខៀវទឹកប៊ិក ក្បាលខ្សែក្រវ៉ាត់ធ្វើពីលោហធាតុលាតពណ៌មាស

-មួកបោណេ ឬបេរ៉េពណ៌ខៀវទឹកប៊ិក។

ចំពោះនារី អាវមានគំរូដូចបុរសតែកាត់តាមរាងដងខ្លួន ខោជើងវែងឬសំពត់ហ្សីបក្រោមជង្គង់ពណ៌ខៀវទឹកប៊ិក។

៣. ឯកសណ្ឋានថ្នាក់អនុសេនីយ៍

-អាវដៃវែងពណ៌ផ្ទៃមេឃ ខោពណ៌ខៀវទឹកប៊ិក កាត់ម៉ូដដូចថ្នាក់អនុសេនីយ៍កងទ័ពជើងគោក

-ស្បែកជើងស្បែក កខ្លីពណ៌ខ្មៅចងខ្សែ ខ្សែក្រវ៉ាត់ពណ៌ខៀវទឹកប៊ិក ក្បាលខ្សែក្រវ៉ាត់ធ្វើពីលោហធាតុលាតពណ៌មាស

-មួកបោណេ ឬបេរ៉េពណ៌ខៀវទឹកប៊ិក។

ចំពោះនារី អាវមានគំរូដូចបុរសតែកាត់តាមរាងដងខ្លួន ខោជើងវែង ឬសំពត់ហ្សីបក្រោមជង្គង់ពណ៌ខៀវទឹកប៊ិក។

៤. ឯកសណ្ឋានថ្នាក់នាយទាហានរង និងពលទាហាន

-អាវដៃវែងពណ៌ផ្ទៃមេឃ ខោពណ៌ខៀវទឹកប៊ិក កាត់ម៉ូដដូចថ្នាក់អនុសេនីយ៍កងទ័ពជើងគោក

-ស្បែកជើងស្បែក កខ្លីពណ៌ខ្មៅចងខ្សែ ខ្សែក្រវ៉ាត់ពណ៌ខៀវទឹកប៊ិក ក្បាលខ្សែក្រវ៉ាត់ធ្វើពីលោហធាតុលាតពណ៌មាស

-មួកបោណេ ឬបេរ៉េពណ៌ខៀវទឹកប៊ិក។

ចំពោះនារី អាវមានគំរូដូចបុរសតែកាត់តាមរាងដងខ្លួន ខោជើងវែង ឬសំពត់ហ្សីបក្រោមជង្គង់ពណ៌ខៀវទឹកប៊ិក។

**មាត្រា ២១.-**

ត្រូវបានរៀបចំឯកសណ្ឋានលេខ៥ សម្រាប់កងទ័ពជើងអាកាសដែលមានរូបភាព និងម៉ូដដូចខាងក្រោម៖

១. ឯកសណ្ឋានថ្នាក់ឧត្តមសេនីយ៍

-អាវ ខោប៉ាភ៉ា កាត់ម៉ូដដូចប៉ាភ៉ាកងទ័ពជើងគោក

-មួកបេរ៉េពណ៌ខៀវទឹកប៊ិក ឬមួកហ្សិកគីប៉ាភ៉ាតាមលំដាប់ថ្នាក់ដូចកងទ័ពជើងគោក ឬមួកដែក

-ស្បែកជើងកវែងប៉ាភ៉ា ឬពណ៌ខ្មៅ ខ្សែក្រវ៉ាត់តូច និងខ្សែសាំងទៀរ៉ុងពណ៌ត្រែអ៊ី។

២. ឯកសណ្ឋានថ្នាក់វរសេនីយ៍ អនុសេនីយ៍ នាយទាហានរង និងពលទាហាន ដូចឯកសណ្ឋានថ្នាក់ឧត្តមសេនីយ៍ដែរ តែមួកហ្សិកគីតាមលំដាប់ថ្នាក់ដូចកងទ័ពជើងគោក។

**មាត្រា ២២.-**

ត្រូវបានរៀបចំឯកសណ្ឋានបច្ចេកទេសជំនាញកងទ័ពជើងអាកាសដូចខាងក្រោម៖

-ឯកសណ្ឋានពណ៌ខៀវ អាវដៃវែង ក្រវ៉ាត់ចង្កេះ ទំហំ ៦ស.ម ដៃអាវដេររាងបំពង់មានក្រវ៉ាត់ដាក់ឡេវហោប៉ៅពីរដេរឃោគ គម្របរាងចតុកោណកែងដេរបង្កប់

-ខោជើងវែងចង្កេះគ្មានក្លី ហោប៉ៅក្រោយដេរបង្កប់ គម្របរាងស្លឹកពោធិនិងមានហោប៉ៅចំហៀងពីរ ដេរបង្កប់តាមថ្នេរខោ ឡេវបង្កប់ថ្នេរឧប ពាក់មួកហ្ស៊ីកកីពណ៌ខៀវ ស្បែកជើងបំពង់កៅស៊ូ កវែងពណ៌ខ្មៅ។ ឯកសណ្ឋានអ្នកបើកបរយន្តហោះគ្រប់ប្រភេទត្រូវរៀបចំតាមប្រភេទយន្តហោះនិងតាមលក្ខណបច្ចេកទេស ជាក់ស្តែង។

**មាត្រា ២៣.-**

ត្រូវបានរៀបចំស្លាកសញ្ញាកងទ័ពជើងអាកាសដូចខាងក្រោម៖

១. សញ្ញាលើហោប៉ៅអាវស្តាំ

-មានរាងជាស្លាបសត្វហង្សពណ៌មាស ដែលជានិមិត្តសញ្ញាកងទ័ពជើងអាកាស មានកម្ពស់៤៣ម.ម និងបណ្តោយ ៨០ម.ម។ នៅចំកណ្តាលស្លាបសត្វហង្សខាងលើមានរូបម្កុដរាជ្យពណ៌មាស មានកាំរស្មីធំប្រាំពីរ កាំរស្មីតូចប្រាំពីរ ផ្នែកខាងក្រោមមានទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជាដែលមានរាងដូចខែល។ រូបសញ្ញានេះផលិតពីលោហធាតុ។

២. សញ្ញាលើ កអាវ

ស្លាកសញ្ញាកងទ័ពជើងអាកាសមានរូបភាពនិងខ្នាតដូចខាងក្រោម៖

រូបភាព: មានរូបស្លាបសត្វនិងរូបម្កុដដាក់ពីលើចំកណ្តាលផលិតពីលោហធាតុពណ៌មាសកម្រាស់ ១ម.ម។ ឯកសណ្ឋានលេខ៥ ឯកសណ្ឋានបច្ចេកទេស និងអ្នកបើកយន្តហោះប៉ាក់ពណ៌មាសដាក់កអាវ ផ្នែកខាងស្តាំ។

ខ្នាត: រូបភាពមានកម្ពស់ ៣០ម.ម ទទឹង ៣៥ម.ម។ នៅចំកណ្តាលមានស្លាបសត្វ បណ្តោយ ១៦ម.ម កម្ពស់១០ម.ម ស្លាបមានពីរជាន់ មួយជាន់ៗមានស្លាប៦។ សម្រាប់នាយទាហាន នាយទាហានរង និងពលទាហានកងទ័ពជើងអាកាសពាក់នៅលើ កអាវ លើកលែងតែកងការពារដែនអាកាស និងកងដឹកជញ្ជូនអាកាសចរណ៍ចេញ ឬជំនាញមួយចំនួនទៀត។

រូបភាពឯកសណ្ឋានគ្រប់ប្រភេទនិងស្លាកសញ្ញានានារបស់កងទ័ពជើងអាកាសមានគំរូដូចក្នុង ឧបសម្ព័ន្ធទី៣នៃអនុក្រឹត្យនេះ។

## ជំពូកទី៥
## ឯកសណ្ឋានកម្មសិក្សានាយទាហាន

**មាត្រា ២៤.-**

ត្រូវបានរៀបចំឯកសណ្ឋាន សម្រាប់កម្មសិក្សានាយទាហានដែលមានរូបភាព និងម៉ូដដូចខាងក្រោម៖

ក-ឯកសណ្ឋានពណ៌គ្រែអ៊ី

-អាវដៃវែង កឧបមានប៉ូលស្មា ហោប៉ៅពីរខាងលើមានគម្របរាងស្លឹកពោធិ ចំកណ្តាលហោប៉ៅមានដេរផ្នត់កាត់ស្រុងវែងដាក់ក្នុងខោ ដៃអាវនៃកដាក់ឡេវពណ៌គ្រែអ៊ី

-ខោជើងវែងចង្កេះគគ្មានក្លី ហោប៉ៅខាងក្រោយពីរដេរបង្កប់មានគម្របរាងស្លឹកពោធិនិងហោប៉ៅពីរទៀតដេរបង្កប់តាមថ្នេរចំហៀង ពីចង្កេះដល់ជើងខោដេរឆ្នូតក្រហមមួយទទឹង ២ស.ម

-មួកបេរ៉េពណ៌គ្រែអ៊ី

-ខ្សែក្រវ៉ាត់ពណ៌គ្រែអ៊ី ក្បាលខ្សែក្រវ៉ាត់ធ្វើពីលោហធាតុលាតពណ៌មាស

-ស្បែកជើងស្បែក កខ្លីពណ៌ខ្មៅចងខ្សែ ស្រោមជើងពណ៌ខ្មៅ។

ខ-សក្តិ សក្តិស្មាមានផ្ទៃពណ៌ខ្មៅក្បាលស្រួចនៅខាងលើផ្ទៃសក្តិមានរូបម្កុដទ្រព្រះខ័ន រូបអាល់ហ្វាទ្រព្រះខ័ន និងសរសេរអក្សរកាត់ឈ្មោះកម្មសិក្សាដូចខាងក្រោម៖

-និស្សិតនាយទាហានសកម្ម សរសេរអក្សរកាត់ **ន.ន.ស** និង

-និស្សិតនាយទាហានទ័ពជើងគោក សរសេរអក្សរកាត់ **ន.ន.ជ.គ**។

ខ្នាតសក្តិដូចសក្តិស្មាកងទ័ពជើងគោក។

រូបភាពឯកសណ្ឋានកម្មសិក្សានាយទាហានមានគំរូដូចក្នុងឧបសម្ព័ន្ធទី៥នៃអនុក្រឹត្យនេះ។

## ជំពូកទី៦

## ឯកសណ្ឋាននិងស្លាកសញ្ញាកម្លាំងពិសេសប្រឆាំងភេរវកម្ម

**មាត្រា ២៥.-**

ត្រូវបានរៀបចំឯកសណ្ឋានគ្រប់ប្រភេទ សម្រាប់កម្លាំងពិសេសប្រឆាំងភេរវកម្ម ដែលមានរូបភាពនិងម៉ូដដូចខាងក្រោម៖

១. ឯកសណ្ឋានធំលេខ១ ឯកសណ្ឋានធំលេខ២ ឯកសណ្ឋានលេខ៣ គ្រប់ថ្នាក់នាយទាហានដូចកងទ័ពជើងគោក។

សម្រាប់នាយទាហានរង និងពលទាហាននៅពេលបំពេញបេសកកម្ម និងទៅសិក្សាក្រៅប្រទេស ឬក្នុងពិធីការជាតិ អាចមានឯកសណ្ឋានលេខ២ និងលេខ៣ដែរ ហើយឯកសណ្ឋាននោះដូចគ្នាថ្នាក់អនុសេនីយ៍តែមួកកាស្កេតនៅហាមមួកគ្មានក្បាច់ភ្ញីទេស ឬឆ្នូតអ្វីទាំងអស់។

២. ឯកសណ្ឋានលេខ៤ គ្រប់ថ្នាក់នាយទាហាន នាយទាហានរង និងពលទាហានដូចកងទ័ពជើងគោក។

៣. ឯកសណ្ឋានលេខ៥ មាន២ប្រភេទគឺ៖

៣.១ ឯកសណ្ឋានលេខ៥អាវជាប់ខោពណ៌ខ្មៅ មួកបេរ៉េពណ៌ដីខ្សាច់ចាស់ មួកហ្សិកកីខ្មៅប៉ាក់រូបព្រះសង្ហារពណ៌មាស ឬមួកដែក ស្បែកជើងកវែងពណ៌ខ្មៅចងខ្សែ។

៣.២ ឯកសណ្ឋានលេខ៥ប៉ារ៉ា មួកហ្សិកកីពណ៌ខ្មៅ បេរ៉េពណ៌ដីខ្សាច់ចាស់ ប៉ាក់រូបព្រះសង្ហារពណ៌មាស ឬមួកដែក ស្បែកជើងកវែងពណ៌ខ្មៅចងខ្សែ។

**មាត្រា ២៦.-**

ត្រូវបានរៀបចំស្លាកសញ្ញាសម្រាប់កម្លាំងពិសេសប្រឆាំងភេរវកម្មដូចខាងក្រោម៖

១. សញ្ញាលើហោប៉ៅអាវស្តាំ

រូបភាព : មានរូបត្រីស្វូល៍និងព្រួញពីរខ្វែងគ្នាចំពីក្រោយព្រមទាំងមានកួរស្រូវនិងផ្កាសន្តិភាពដែលមានរាងជាស្លែងក្របីអមសងខាង ផ្នែកខាងក្រោមមានបូរុំកួរស្រូវនិងផ្កាសន្តិភាពហើយមានអក្សរកាត់ **គ.ជ.ម.ភ** នៅចំកណ្តាល។

ខ្នាត : ទទឹង ៥១ម.ម កម្ពស់ ៥៩ម.ម ត្រីស្វូល៍កម្ពស់ ៥៩ម.ម និងទទឹង ២១.៧០ម.ម ព្រួញខ្វែងគ្នាប្រវែង ៣៨.៧០ម.ម កួរស្រូវប្រវែង៥០ម.ម ទទឹង៦.៨ម.ម ផ្កាសន្តិភាពប្រវែង៥០ម.ម ទទឹង៦.៨ម.ម។ សញ្ញានេះធ្វើពីលោហធាតុ និងប៉ាក់លើក្រណាត់ដេរភ្ជាប់លើហោប៉ៅអាវ។

២. សញ្ញាលើ កអាវ ពាក់សញ្ញាថ្មើរជើងដូចកងទ័ពជើងគោក។

រូបភាពឯកសណ្ឋាននិងស្លាកសញ្ញាកម្លាំងពិសេសប្រឆាំងភេរវកម្មមានគំរូដូចក្នុងឧបសម្ព័ន្ធទី៥នៃអនុក្រឹត្យនេះ។

## ជំពូកទី៧

## ឯកសណ្ឋាននិងស្លាកសញ្ញាកងរាជអាវុធហត្ថ

**មាត្រា ២៧.-**

ត្រូវបានរៀបចំឯកសណ្ឋានធំលេខ១ សម្រាប់កងរាជអាវុធហត្ថដែលមានរូបភាព និងម៉ូដដូចខាងក្រោម៖

ឯកសណ្ឋានថ្នាក់ឧត្តមសេនីយ៍ ឯកសណ្ឋានថ្នាក់វរសេនីយ៍ ឯកសណ្ឋានថ្នាក់អនុសេនីយ៍ ដូចកងទ័ពជើងគោក។

ចំពោះនារី ដូចឯកសណ្ឋាននារីកងទ័ពជើងគោក។

**មាត្រា ២៨.-**

ត្រូវបានរៀបចំឯកសណ្ឋានធំលេខ២ សម្រាប់កងរាជអាវុធហត្ថដែលមានរូបភាព និងម៉ូដដូចខាងក្រោម៖

១. ឯកសណ្ឋានថ្នាក់ឧត្តមសេនីយ៍ អាវពណ៌ប្រផេះ ខោពណ៌ត្រែអ៊ី មួកកាស្កេតពណ៌ប្រផេះ អាវសឹមីពណ៌កាគីខ្ចី ក្រវ៉ាត់កពណ៌ទឹកប៊ិកចាស់ កាត់ម៉ូដដូចឯកសណ្ឋានថ្នាក់ឧត្តមសេនីយ៍កងទ័ពជើងគោក។ ដោយឡែកផ្ទៃសក្តិពណ៌ខៀវទឹកប៊ិក។

២. ឯកសណ្ឋានថ្នាក់វរសេនីយ៍ អាវពណ៌ប្រផេះ ខោពណ៌ត្រែអ៊ី មួកកាស្កេតពណ៌ប្រផេះ អាវសឹមីពណ៌ត្រែអ៊ីខ្ចី ក្រវ៉ាត់កពណ៌ទឹកប៊ិកចាស់ កាត់ម៉ូដដូចឯកសណ្ឋានថ្នាក់វរសេនីយ៍កងទ័ពជើងគោក។

៣. ឯកសណ្ឋានថ្នាក់អនុសេនីយ៍ អាវពណ៌ប្រផេះ ខោពណ៌ត្រែអ៊ី មួកកាស្កេតពណ៌ប្រផេះ អាវសឹមីពណ៌ត្រែអ៊ីខ្ចី ក្រវ៉ាត់កពណ៌ទឹកប៊ិកចាស់ កាត់ម៉ូតដូចឯកសណ្ឋានថ្នាក់អនុសេនីយ៍កងទ័ពជើងគោក។

ចំពោះនារី អាវមានគំរូដូចបុរសតែកាត់តាមរាងដងខ្លួន និងសំពត់ហ្ស៊ីបក្រោមជង្គង់ពណ៌ត្រែអ៊ី។

ថ្នាក់នាយទាហានរង និងពលទាហាននៅបំពេញបេសកកម្ម និងទៅសិក្សាក្រៅប្រទេស ឬក្នុងពិធីការជាតិធំៗ អាចមានឯកសណ្ឋានធំលេខ២។ ឯកសណ្ឋានទាំងនោះដូចថ្នាក់អនុសេនីយ៍ តែមួកកាស្កេតនៅហាមមួកគ្មានក្បាច់ភ្ញីទេស ឬឆ្នូតអ្វីទាំងអស់។

**មាត្រា ២៩.-**

ត្រូវបានរៀបចំឯកសណ្ឋានលេខ៣ សម្រាប់កងរាជអាវុធហត្ថដែលមានរូបភាព និងម៉ូដដូចខាងក្រោម៖

១. ឯកសណ្ឋានថ្នាក់ឧត្តមសេនីយ៍ អាវពណ៌ប្រផេះ ខោពណ៌ត្រែអ៊ី មួកកាស្កេតពណ៌ប្រផេះកាត់ម៉ូដដូចឯកសណ្ឋានថ្នាក់ឧត្តមសេនីយ៍កងទ័ពជើងគោក ខុសត្រង់គម្រប់ហោប៉ៅអាវមានរាងស្លឹកពោធិ ផ្ទៃសក្តិពណ៌ខៀវទឹកប៊ិក។

២. ឯកសណ្ឋានថ្នាក់វរសេនីយ៍ អាវពណ៌ប្រផេះ ខោពណ៌ត្រែអ៊ី មួកកាស្កេតពណ៌ប្រផេះ កាត់ម៉ូដដូចឯកសណ្ឋានថ្នាក់វរសេនីយ៍កងទ័ពជើងគោក ខុសត្រង់គម្រប់ហោប៉ៅអាវមានរាងស្លឹកពោធិ ផ្ទៃសក្តិពណ៌ខៀវទឹកប៊ិក។

៣. ឯកសណ្ឋានថ្នាក់អនុសេនីយ៍ អាវពណ៌ប្រផេះ ខោពណ៌ត្រែអ៊ី មួកកាស្កេតពណ៌ប្រផេះកាត់ម៉ូដដូចឯកសណ្ឋានថ្នាក់អនុសេនីយ៍កងទ័ពជើងគោក ខុសត្រង់គម្រប់ហោប៉ៅអាវមានរាងស្លឹកពោធិ ផ្ទៃសក្តិពណ៌ខៀវទឹកប៊ិក។

ចំពោះនារី អាវមានគំរូដូចបុរសតែកាត់តាមរាងដងខ្លួន និងសំពត់ហ្ស៊ីបក្រោមជង្គង់ពណ៌ត្រែអ៊ី។

ថ្នាក់នាយទាហានរងនិងពលទាហាននៅពេលបំពេញបេសកកម្ម និងទៅសិក្សាក្រៅប្រទេស ឬក្នុងពិធីការជាតិធំៗ អាចមានឯកសណ្ឋានលេខ៣។ ឯកសណ្ឋានទាំងនោះដូចថ្នាក់អនុសេនីយ៍ តែមួកកាស្កេតគ្មានក្បាច់ភ្ញីទេស ឬខ្នូតអ្វីទាំងអស់។

**មាត្រា ៣០.-**

ត្រូវបានរៀបចំឯកសណ្ឋានលេខ៤ សម្រាប់កងរាជអាវុធហត្ថដែលមានរូបភាព និងម៉ូដដូចខាងក្រោម៖

-អាវដៃវែងក្រណាត់ពណ៌ប្រផេះ កឧបមានប៉ូលស្មាកាត់ស្រួចវែង ហោប៉ៅពីរដេរប៉ះ ចំកណ្តាលដេរបត់ផ្នត់មួយមានគម្របរាងស្លឹកពោធិ ឡេវតូចពណ៌ប្រផេះ ចុងដៃអាវមានផែកនិងដាក់ឡេវ

-ខោជើងវែងពណ៌គ្រេអ៊ី ចង្កេះគគ្មានភ្លី ហោប៉ៅពីរខាងក្រោយដេរបង្កប់មានគម្របរាងស្លឹកពោធិ និងហោប៉ៅពីរទៀតដេរបង្កប់តាមថ្នេរចំហៀងរបស់ខោ

-មួកបេរ៉េ ក្រណាត់កម្លីពណ៌ខៀវទឹកប៊ិកពាក់បញ្ឆិតខាងឆ្វេង រូបព្រះសង្ហារខាងស្តាំ។

ចំពោះនារីអាវដូចបុរស សំពត់ហ្ស៊ីបក្រោមជង្គង់ឬខោឡេវរូតចំហៀង។

ឯកសណ្ឋាននេះប្រើគ្រប់ឋានន្តរសក្តិ។

**មាត្រា ៣១.-**

ត្រូវបានរៀបចំឯកសណ្ឋានជំនាញ សម្រាប់កងរាជអាវុធហត្ថដែលមានរូបភាព និងម៉ូដដូចខាងក្រោម៖

-អាវដៃវែងក្រណាត់កាគីពណ៌គ្រេអ៊ី កបើកថ្នេរឧបមានឡេវបង្កប់នៅចុងដៃអាវ រង្វង់ដៃបំពង់មានឡេវក្រេវ៉ាត់ កាត់ស្រួចវែងដាក់ក្នុងខោ

-ខោជើងវែងក្រណាត់កាគីពណ៌គ្រេអ៊ី ចង្កេះគគ្មានភ្លី ថ្នេរឧប ហោប៉ៅខាងក្រោយពីរដេរបង្កប់មានគម្របរាងស្លឹកពោធិ ហោប៉ៅពីរនៅចំហៀងតាមថ្នេរខោដេរបង្កប់មាត់បញ្ឆិត ប៉ានជង្គង់ ជើងខោចងខ្សែ

-ស្បែកជើងស្បែក កវែងពណ៌ខ្មៅចងខ្សែ និងស្រោមជើងពណ៌ខ្មៅ

-មួកស៊ីកាស ឬបេរ៉េពណ៌ខៀវទឹកប៊ិក

-ពាក់សក្តិកអាវ ផ្ទៃសក្តិពណ៌ខៀវទឹកប៊ិក។

**មាត្រា ៣២.-**

ត្រូវបានរៀបចំឯកសណ្ឋានលេខ៥ សម្រាប់កងរាជអាវុធហត្ថដែលមានរូបភាព និងម៉ូដដូចខាងក្រោម៖

-ខោ អាវពណ៌ទឹកប៊ិកចាស់ កាត់ម៉ូដដូចឯកសណ្ឋានប្រយុទ្ធកងទ័ពជើងគោក តែប្រើខ្សែចងចង្កេះ

-មួកដែក ឬមួកបេរ៉េពណ៌ខៀវទឹកប៊ិក

-ស្បែកជើងស្បែក កវែងពណ៌ខ្មៅចងខ្សែ ស្រោមជើងពណ៌ខ្មៅ។

ឯកសណ្ឋាននេះប្រើគ្រប់ឋានន្តរសក្តិ។

**មាត្រា ៣៣.-**

ត្រូវបានរៀបចំឯកសណ្ឋាន សម្រាប់កងយានយន្តកិត្តិយសដែលមានរូបភាព និងម៉ូដដូចខាងក្រោម៖

-អាវធំលេខ២ក្រណាត់ពណ៌ប្រផេះ

-ខោពណ៌គ្រេអ៊ីកាត់ម៉ូដដូចខោជំនាញ

-មួកស៊ីកាសពណ៌ខៀវទឹកប៊ិកឬមួកប៉េកម៉ូត

-ស្បែកជើងស្បែកកវែងពណ៌ខ្មៅចងខ្សែ កន្សែងរុំក(ហ្វូឡា) .ណ៌ខៀវទឹកប៊ិកពាក់ស្រោមដៃពណ៌ស ខ្សែកញ្ចែពណ៌មាស

-ខ្សែក្រវ៉ាត់ធំធ្វើពីស្បែកពណ៌ស ក្បាលខ្សែក្រវ៉ាត់មានរូបសញ្ញាកងរាជអាវុធហត្ថ។

**មាត្រា ៣៤.-**

ត្រូវបានរៀបចំសក្តិរបស់កងរាជអាវុធហត្ថដូចខាងក្រោម៖

-សក្តិសម្រាប់ពាក់លើឯកសណ្ឋានលេខ១ដូចកងទ័ពជើងគោក

-សក្តិសម្រាប់ពាក់លើឯកសណ្ឋានលេខ២ ឯកសណ្ឋានលេខ៣ ឯកសណ្ឋានលេខ៤ រូបភាពខ្នាត ដូចសក្តិស្មាកងទ័ពជើងគោក តែផ្ទៃសក្តិពណ៌ខៀវទឹកប៊ិក

-សក្តិសម្រាប់ឯកសណ្ឋានលេខ៥ និងឯកសណ្ឋានជំនាញដូចសក្តិកអាវកងទ័ពជើងគោក តែផ្ទៃ សក្តិពណ៌ខៀវទឹកប៊ិក។

**មាត្រា ៣៥.-**

ត្រូវបានរៀបចំស្លាកសញ្ញា កងរាជអាវុធហត្ថដូចខាងក្រោម៖

១- សញ្ញាលើ កអាវ មាន២ប្រភេទ។

ប្រភេទទី១

រូបភាព : មានរាងពងក្រពើ ផ្នែកខាងលើគឺជាសៀវភៅតំណាងឲ្យច្បាប់ និងពន្លឺទាំង១២តំណាងឲ្យ ខែឆ្នាំទាំង១២ ផ្នែកខាងក្នុងមានព្រះខ័នបញ្ឈរ អមសងខាងផ្លែព្រះខ័នមានអក្សរកាត់ **អហ** (**អ**នៅខាងឆ្វេង **ហ**នៅខាងស្តាំ) លើដងព្រះខ័នមានរូបស្លាបសត្វ (ម្ខាង៧ស្លាប) និងរូបយុថ្កាដែលមានផ្លែសងខាងទ្រស្លាប សត្វ។

ខ្នាត : កម្ពស់រូបភាព ៣.៥០ស.ម ទទឹង ២.២០ស.ម កម្ពស់ព្រះខ័ន ២.៨៥ស.ម។

សញ្ញានេះផលិតពីលោហធាតុពណ៌មាស កម្រាស់១.៥០ម.ម និងផលិតពីក្រណាត់ពណ៌ទឹកប៊ិក ចាស់មានប៉ាក់រូបដូចខាងលើពីអំបោះពណ៌មាសដេរភ្ជាប់ កអាវខាងស្តាំ។

ប្រភេទទី២

រូបភាព : មានរាងមូល មានកួរស្រូវអមសងខាងតំណាងឲ្យភោគផលកសិកម្មនៅចំកណ្តាលកួរស្រូវ មានរូបជញ្ជីងបញ្ឈរតំណាងឲ្យភាពយុត្តិធម៌ ខាងលើជញ្ជីងមានរូវសៀវភៅរៀបរាងកោងតម្រាបគ្នាតំណាង ឲ្យច្បាប់។

ខ្នាត : កម្ពស់រូបភាព ៣.១៨ស.ម ទទឹង៣ស.ម។

សញ្ញានេះផលិតពីលោហធាតុពណ៌មាស កម្រាស់១.៥០ម.ម និងផលិតពីក្រណាត់ពណ៌ទឹកប៊ិក ចាស់មានប៉ាក់រូបដូចខាងលើពីអំបោះពណ៌មាសដេរភ្ជាប់កអាវខាងស្តាំ។ ស្លាកសញ្ញានេះប្រើសម្រាប់តែ យោធិនដែលមាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌។

២- ស្លាកសញ្ញាកងរាជអាវុធហត្ថលើហោប៉ៅអាវ

ស្លាកសញ្ញាកងរាជអាវុធហត្ថលើហោប៉ៅអាវខាងឆ្វេងមានរាងមូលផលិតពីដែកក្រូមេ ឬដែកអ៊ីន ណុកដែលមានអង្កត់ផ្ចិតរង្វង់ក្រៅប្រវែង ៧ស.ម និងអង្កត់ផ្ចិតរង្វង់ក្នុងមានប្រវែង ៥.៦ស.ម។

រង្វង់ខាងក្នុង ផ្នែកខាងលើនិងខាងក្រោមពណ៌ទឹកប៊ិក កម្ពស់ ១.៨ស.ម និងកណ្តាលពណ៌ក្របាម ប្រវែង២.៨ស.ម។ រង្វង់ក្នុង(តូច) មានរូបសញ្ញាព្រះខ័ន ផ្លែពណ៌ស ដងពណ៌លឿងចាស់ដាក់បញ្ឈរចំកណ្តាល

តំណាងឲ្យអ្នកការពារច្បាប់។ នៅសងខាងអមផ្លែព្រះខ័នមានចារឹកអក្សរកាត់ពីរតួ ពណ៌សតី **អ.ហ** កម្ពស់ ២.៣ស.ម តំណាងឲ្យអង្គភាពកងរាជអាវុធហត្ថ។ នៅដងព្រះខ័នមានរូបលំពែងពណ៌លឿង តំណាងឲ្យកងទ័ពជើងគោក។នៅលើដងខាងក្រោមលំពែង ទម្រសងខាងមានរូបស្លាបសត្វ ដែលមានស្លាបម្ខាងៗប្រាំពីរ ពណ៌មាសតំណាងឲ្យកងទ័ពជើងអាកាស។

រង្វង់ខាងក្រៅ នៅចុងខាងក្រោមដងព្រះខ័នមាន រូបយុថ្កាពណ៌ខ្មៅ និងខ្សែវណ្ណយុថ្កាពណ៌ស តំណាងឲ្យកងទ័ពជើងទឹក។ ផ្នែកខាងក្រៅក្នុងរង្វង់កណ្ដាល អមសងខាងមានកួរស្រូវ (ម្ខាងៗមានប្រាំពីរថ្នាក់) រំលេចដោយពណ៌មាសតំណាងកោតផលកសិកម្ម។ ខាងក្រោមដងព្រះខ័នមានដាក់លេខរៀងពណ៌ទឹកប៊ិកសម្រាប់សម្គាល់ កងរាជអាវុធហត្ថម្នាក់ៗកាន់កាប់ស្លាក។ ផ្នែកខាងលើចុងព្រះខ័នមានចារឹកអក្សរ **កងរាជអាវុធហត្ថ** ពណ៌ទឹកប៊ិកកម្ពស់០.៤ស.ម។

រូបភាព ឯកសណ្ឋានគ្រប់ប្រភេទ និងស្លាកសញ្ញារបស់កងរាជអាវុធហត្ថមានគំរូដូចក្នុងឧបសម្ព័ន្ធទី៦ នៃអនុក្រឹត្យនេះ។

## ជំពូកទី៨

## ឯកសណ្ឋាន កងត្រៃទ័ព និងកងកិត្តិយស

**មាត្រា ៣៦**.-

ត្រូវបានរៀបចំឯកសណ្ឋានកងត្រៃទ័ព ដូចខាងក្រោម៖

-ជាប្រភេទអាវកុដពណ៌ស មានហោប៉ៅ៤ ខាងលើ២ដេរប៉ះមានគម្របរាងស្លឹកពោធិ មានឡេវរូបព្រះសង្ហារពណ៌មាស ខាងក្រោម២ដេរបង្កប់គម្របហោប៉ៅរាងស្លឹកពោធិមានឡេវរូបព្រះសង្ហារពណ៌មាស។ សក្តិស្មាពណ៌មាស ឡេវអាវរូបព្រះសង្ហារពណ៌មាសចំនួន៦ កអាវមានប៉ាក់ភ្ញីទេសពណ៌មាស ទំហំ៣០ម.ម ចុងដៃអាវមានប៉ាក់ភ្ញីពណ៌មាសទំហំ២០ម.ម មានឆ្នូតបង្កង់២ ទំហំ១០ម.ម ពណ៌មាស និងរូបវណ្ណ១នៅលើបង្កង់ពណ៌មាស

-មួកកាស្កេតពណ៌ស ជើងមួកពណ៌ខ្មៅ លម្អដោយខ្សែវណ្ណពណ៌មាស មានរូបព្រះសង្ហារពណ៌មាស ហាមមួកពណ៌ខ្មៅ រំលេចដោយក្បាច់ភ្ញីពណ៌មាស មានខ្សែស្បែកពណ៌ខ្មៅរឹបនឹងចង្កា

-ខោជើងវែងពណ៌ខ្មៅមានឆ្នូត២ពណ៌លឿង ឆ្នូតនីមួយៗ មានទំហំ២០ម.ម ជើងខោរាងស្តួចចាប់ពីក្បាលជង្គង់ចុះទៅក្រោម

-ស្បែងជើងកវែងពណ៌ខ្មៅ ប្រវែងត្រឹមក្បាលជង្គង់

-សក្តិស្មាពណ៌មាស មានរឹមព័ទ្ធជុំវិញ

-ខ្សែឥស្សរិយយសពណ៌មាស (ចំនួន៣ខ្សែវេញបញ្ចូលគ្នា ពីត្រឹមស្មាដល់កន្លែងព្យួរឡេវអាវ ចាប់ពីត្រឹមឡេវអាវមកសល់១ខ្សែ ក្បាលមានតែ១) ស្លាកឈ្មោះ រូបហនុមានពាក់នៅលើហោប៉ៅអាវខាងស្តាំ គ្រឿងឥស្សរិយយសពាក់នៅលើហោប៉ៅអាវខាងឆ្វេង

-ខ្សែក្រវ៉ាត់ធំធ្វើពីស្បែកពណ៌ស ទំហំ៧០ម.មក្រវ៉ាត់ពីលើអាវ និងស្រោមដៃពណ៌ស។

**មាត្រា ៣៧**.-

ត្រូវបានរៀបចំឯកសណ្ឋានកងកិត្តិយសកងទ័ពទាំង៣ប្រភេទ កងសាប និងពិធីបុណ្យសពដូចខាងក្រោម៖

១-ឯកសណ្ឋានកងកិត្តិយសកងទ័ពជើងគោក

-ជាប្រភេទអាវកុដពណ៌ក្រហម មានហោប៉ៅ៤ ខាងលើ២ដេរប៉ះមានគម្របរាងស្លឹកពោធិមានឡេវ

រូបព្រះសង្ហារពណ៌មាស ខាងក្រោម២ដេរបង្កប់គម្របហោប៉ៅកងស្លឹកពោធិ មានឡេវរូបព្រះសង្ហារ ពណ៌មាស សក្តិស្មាពណ៌មាស ឡេវអាវរូបព្រះសង្ហារពណ៌មាសចំនួន៦ កអាវមានប៉ាក់ភ្ជីពណ៌មាសទំហំ៣០ម.ម ចុងដៃអាវមានប៉ាក់ភ្ជីទេសពណ៌មាសទំហំ ២០ម.ម មានឆ្នូតបង្កង់២ ទំហំ១០ម.ម ពណ៌មាស និងរូបវណ្ឌ១ ពណ៌មាសនៅពីលើបង្កង់

-មួកកាស្កេតពណ៌ខ្មៅ ជើងមួកពណ៌ក្រហម លម្អដោយខ្សែវណ្ឌពណ៌មាស មានរូបព្រះសង្ហារពណ៌មាស ហាមមួកពណ៌ខ្មៅ រំលេចដោយក្បាច់ភ្ជីពណ៌មាស មានខ្សែស្បែក ពណ៌ខ្មៅរឹបនឹងចង្កា

-ខោជើងវែងពណ៌ខ្មៅមានឆ្នូត២ពណ៌ក្រហម ឆ្នូតនីមួយៗមានទំហំ២០ម.ម ជើងខោកងស្លូចចាប់ពីក្បាលជង្គង់ចុះទៅក្រោម

-ស្បែងជើងកវែងពណ៌ខ្មៅ ប្រវែងត្រឹមក្បាលជង្គង់

-សក្តិស្មាពណ៌មាស មានរឹមព័ទ្ធជុំវិញ

-ខ្សែឥស្សរិយយស ពណ៌មាស (ចំនួន៣ខ្សែវេញបញ្ចូលគ្នា ពីត្រឹមស្មាដល់កន្លែងព្យួរឡេវអាវ ចាប់ពីត្រឹមឡេវអាវមកសល់១ខ្សែក្បាលមានតែ១)ស្លាកឈ្មោះរូបហានុមានពាក់នៅលើហោប៉ៅអាវខាងស្តាំ គ្រឿងឥស្សរិយយសពាក់នៅលើហោប៉ៅអាវខាងឆ្វេង

-ខ្សែក្រវ៉ាត់ធំធ្វើពីស្បែកពណ៌សទំហំ ៧០ម.ម ក្រវ៉ាត់ពីលើអាវ និងស្រោមដៃពណ៌ស។

២- ឯកសណ្ឋានកងកិត្តិយសកងទ័ពជើងទឹក

ជាប្រភេទអាវកុដពណ៌ស មានរូបភាព ម៉ូដ និងខ្នាតដូចឯកសណ្ឋានកងកិត្តិយសកងទ័ពជើងគោក តែខោពណ៌ស មួកពណ៌ស ជើងមួកពណ៌ទឹកសមុទ្រ។

៣- ឯកសណ្ឋានកងកិត្តិយសកងទ័ពជើងអាកាស

ជាប្រភេទអាវកុដពណ៌ខៀវទឹកប៊ិក មានរូបភាព ម៉ូដ និងខ្នាតដូចឯកសណ្ឋានកងកិត្តិយសកងទ័ពជើងគោក តែខោពណ៌ខៀវទឹកប៊ិក មួកពណ៌ខៀវទឹកប៊ិក ជើងមួកពណ៌ក្រហម។

៤- ឯកសណ្ឋានកងកិត្តិយសកងសាប(ដាវ)

ជាប្រភេទអាវកុដពណ៌ស ខោពណ៌ខ្មៅ មានរូបភាព ម៉ូដ និងខ្នាតដូចឯកសណ្ឋានកងកិត្តិយស កងទ័ពជើងគោក ប្រើដាវមានស្រោមពណ៌ស ខ្សែរំយោលដាវពណ៌មាស ដងដាវឆ្លាក់រូបព្រហ្មមុខ៤ ផ្លែដាវពណ៌ប្រាក់ ចង្កំនិងដងដាវក្បាច់ពណ៌មាស។

៥- ឯកសណ្ឋានពិធីបុណ្យសព

អាវធំលេខ២ ពណ៌ស ខោពណ៌ខ្មៅគ្មានឆ្នូត អាវសឺមីក្នុងដៃវែងពណ៌ស ពាក់ក្រវ៉ាត់កពណ៌ខ្មៅ មួកកាស្កេតពណ៌ស ជើងមួកពណ៌ខ្មៅ ស្បែកជើងកវែងពណ៌ខ្មៅត្រឹមក្បាលជង្គង់ សក្តិស្មា (ផ្ទៃពណ៌ខ្មៅ) ខ្សែ-ឥស្សរិយយសពណ៌មាស ខ្សែក្រវ៉ាត់ស្បែកពណ៌ខ្មៅ ទំហំ៧០ម.ម ក្រវ៉ាត់ពីលើអាវ និងស្រោមដៃពណ៌ស។

រូបភាពឯកសណ្ឋានកងត្រៃទ័ពនិងកងកិត្តិយស មានគំរូដូចក្នុងឧបសម្ព័ន្ធទី៧នៃអនុក្រឹត្យនេះ។

**មាត្រា ៣៤.-**

ត្រូវបានរៀបចំឯកសណ្ឋានកងកិត្តិយសតាមបញ្ជាការដ្ឋានកងទ័ពទាំង៣ប្រភេទ កងរាជអាវុធហត្ថ បណ្តាយោធភូមិភាគ កងពល និងអង្គភាពចំណុះដូចខាងក្រោម៖

១- បញ្ជាការដ្ឋានកងទ័ពជើងគោក

ឯកសណ្ឋានធំលេខ២ កងទ័ពជើងគោក ដូចមានចែងក្នុងមាត្រា៤ ត្រង់ចំណុច២និងចំណុច៣នៃអនុក្រឹត្យនេះ។

២- បញ្ជាការដ្ឋានកងទ័ពជើងទឹក

ឯកសណ្ឋានធំលេខ២ កងទ័ពជើងទឹក ដូចមានចែងក្នុងមាត្រា១១ ត្រង់ចំណុច២ និងចំណុច៣នៃអនុក្រឹត្យនេះ។

៣- បញ្ជាការដ្ឋានកងទ័ពជើងអាកាស

ឯកសណ្ឋានធំលេខ២ កងទ័ពជើងអាកាស ដូចមានចែងក្នុងមាត្រា១៨ ត្រង់ចំណុច២ និងចំណុច៣ នៃអនុក្រឹត្យនេះ។

៤- បញ្ជាការដ្ឋានកងរាជអាវុធហត្ថ

ឯកសណ្ឋានលេខ២កងរាជអាវុធហត្ថ ដូចមានចែងក្នុងមាត្រា២៨ ត្រង់ចំណុច២ និងចំណុច៣នៃអនុក្រឹត្យនេះ។

៥- ឯកសណ្ឋានកងកិត្តិយសតាមបណ្តាយោធភូមិភាគ កងពលនិងអង្គភាពចំណុះ

ឯកសណ្ឋានលេខ៥ ពាក់មួកបេរ៉េកក៏ឬមួកដែក (ឯកភាពគ្នា) និងស្រោមដៃពណ៌ស។

## ជំពូកទី៩

## បរិក្ខាររួមផ្សំ

**មាត្រា ៣៩.-**

ត្រូវបានរៀបចំស្លាកសញ្ញាសម្រាប់ប្រើជាទូទៅក្នុងកងយោធពលខេមរភូមិន្ទ និងបរិក្ខាររួមផ្សំរបស់កងរាជអាវុធហត្ថដូចខាងក្រោម៖

១- រូបព្រះសង្ហារ

-រូបព្រះសង្ហារយកតាមសញ្ញាជាតិធ្វើពីលោហធាតុពណ៌មាស នៅលើវ័ណ្ឌព្រះសង្ហារមានសរសេរអក្សរ **ព្រះរាជាណាចក្រកម្ពុជា** កម្ពស់ ៧.៨ស.ម និងមានទទឹង ៦.៥ស.ម។

-រូបព្រះសង្ហារយកតាមសញ្ញាជាតិធ្វើពីអំបោះពណ៌មាស ប៉ាក់ភ្ជាប់និងមួក។

២- ស្លាកសញ្ញាកងយោធពលខេមរភូមិន្ទ

ក- ស្លាកសញ្ញានៅលើដៃអាវស្តាំ

មានរាងមូលអង្កត់ផ្ចិត៨ស.ម ស្រទាប់ខាងក្រៅពណ៌ស ទទឹងស្រទាប់នេះ៣ម.ម ផ្ទៃខាងលើ១/៤នៃរង្វង់មានពណ៌ខៀវ ហើយសរសេរអក្សរពណ៌ស ផ្នែកខាងលើកោងតាមរង្វង់ ចារឹកអក្សរថា **ព្រះរាជាណាចក្រកម្ពុជា** កម្ពស់អក្សរ ៥ម.ម ផ្ទៃកណ្តាល ១/២ នៃរង្វង់មានពណ៌ក្រហម ហើយមាន ប្រាសាទអង្គរវត្តកំពូលបីពណ៌ស កម្ពស់ប្រាសាទ ២.៥ស.ម ផ្ទៃខាងក្រោម ១/៤ នៃរង្វង់មានពណ៌ខៀវ សរសេរអក្សរកាត់ពណ៌សថា **ខ.ភ.ម** កម្ពស់អក្សរ ៧ម.ម ផលិតពីក្រណាត់ អាចបោះពុម្ពឬប៉ាក់។

ខ-ស្លាកសញ្ញារូបហនុមាន

មានរាងមេដាយ បន្តោងនៅឡេវហោប៉ៅអាវស្តាំ ស្លាកសញ្ញាធ្វើពីលោហធាតុ ផ្នែកខាងលើមានម្កុដពណ៌មាស មានកាំរស្មីប្រាំពីរ សងខាងមានរំយោលម្ខាងបីពណ៌មាស (តំណាងឲ្យទង់ជាតិ) ផ្នែកកណ្តាលពណ៌ទឹកប៊ិក លើផ្ទៃកណ្តាលមានរូបហនុមានកាន់ព្រះខ័នកំពុងសំដែងរិទ្ធិពណ៌ស្លាទុំ នៅផ្នែកខាងក្រោមមានជើងពានរាងដូចស្នែងក្របីផ្ទៃពណ៌ក្រហម រឹមជុំវិញពណ៌មាសនៅផ្ទៃនោះសរសេរ អក្សរកាត់ថា **ខ.ភ.ម** ពណ៌មាស។ កម្ពស់រូបភាព ៦០ម.ម ទទឹង ៤៥ម.ម កម្ពស់ម្កុដ ២៧ម.ម បាតក្រោមម្កុដ ៣៨ម.ម។ ផ្ទៃកណ្តាលពណ៌ខៀវ កម្ពស់ ៣២ម.ម ទទឹង ៣០ម.ម រូបហនុមាន មានកម្ពស់ ២៨ម.ម។ រំយោលសងខាងទីមួយប្រវែង ១៦ម.ម ទីពីរប្រវែង ១៤ម.ម ទីបី ១២ម.ម។ ជើងពានផ្នែកខាងក្រោមមានរាងដូចស្នែងក្របី

បណ្ដោយប្រវែង ៣៥ម.ម ទទឹង ៦ម.ម កម្ពស់អក្សរ ៥ម.ម។ សញ្ញាដាក់លើស្បែក សម្រាប់ពាក់នឹងខ្សែរហោប៉ៅអាវស្ដាំប្រវែងពីលើមកដល់ក្រោម ១០០ម.ម។

គ- ស្លាកឈ្មោះនិងស្លាកអក្សរ ខ.ភ.ម

ស្លាកឈ្មោះលើហោប៉ៅអាវស្ដាំធ្វើពីជ័រប្លាស្ទិកផ្ទៃពណ៌ខ្មៅគូសបន្ទាត់ជុំវិញពណ៌មាស បណ្ដោយស្លាក ១០ស.ម ទទឹង២ស.ម កម្ពស់អក្សរ ៧ម.ម ពណ៌មាស សរសេរជាអក្សរខ្មែរហើយអាចធ្វើស្លាកឈ្មោះដែលមានផ្ទៃនិងទំហំដូចគ្នាជាអក្សរឡាតាំងមួយទៀត មិនបានសរសេរក្នុងស្លាកតែមួយ អក្សរខ្មែរផង និងអក្សរឡាតាំងផងឡើយ ឬដាក់ស្លាកសញ្ញាផ្សេងៗទៀតលើស្លាកឈ្មោះទេ។ នៅខាងដើមនាមត្រកូលនិងនាមខ្លួនត្រូវសរសេរ អក្សរកាត់ឋានន្តរសក្តិរបស់យោធិនម្នាក់ៗ គឺយកតែអក្សរទីមួយនៃឈ្មោះសក្តិ ចំពោះអក្សរឡាតាំងភាសារ អង់គ្លេស ឬ បារាំងយកតាមការសរសេរអក្សរកាត់ដែលគេបានកំណត់ជាទូទៅនៃអន្តរជាតិ។

ចំពោះឯកសណ្ឋានលេខ៥ដាក់ស្លាកឈ្មោះធ្វើពីក្រណាត់ពណ៌គ្រែអ៊ី ប្រវែងស្មើហោប៉ៅ ទទឹង២ស.ម សរសេរអក្សរពណ៌ខ្មៅដេរភ្ជាប់លើហោប៉ៅអាវស្ដាំ និងកម្ពស់អក្សរ ៧ម.ម។ លើហោប៉ៅអាវខាងឆ្វេងដេរភ្ជាប់ស្លាកអក្សរ **ខ.ភ.ម** ផ្ទៃពណ៌គ្រែអ៊ី អក្សរពណ៌ខ្មៅប្រវែងស្មើហោប៉ៅ ទទឹង២ស.ម កម្ពស់អក្សរ ៧ម.ម។

ដោយឡែកស្លាកឈ្មោះកងរាជអាវុធហត្ថ ធ្វើពីជ័រប្លាស្ទិក ផ្ទៃពណ៌ទឹកប៊ិករាងបួនជ្រុងទ្រវែងមានបណ្ដោយ ១២ស.ម និងទទឹងប្រវែង ២ស.ម ពាក់ខាងលើគម្របហោប៉ៅអាវស្ដាំ។ ស្លាកឈ្មោះជាអក្សរជាតិអក្សរមូលពណ៌ស បញ្ឈរ ដែលមានទំហំ ១៥ម.ម ខាងមុខអក្សរឈ្មោះ ប៉ាក់អក្សរកាត់តាមឋានន្តរសក្តិ ឧត្តមសេនីយ៍ប៉ាក់អក្សរ **ឧ** វរសេនីយ៍ប៉ាក់អក្សរ **វ** អនុសេនីយ៍ប៉ាក់អក្សរ **អ** នាយចំណង់ប៉ាក់អក្សរ **ន** ព្រិន្ទបាលប៉ាក់អក្សរ **ព្រ** ពលបាលប៉ាក់អក្សរ **ព**។ ចំពោះឯកសណ្ឋានជំនាញ និងឯកសណ្ឋានលេខ៥ស្លាកឈ្មោះធ្វើពីក្រណាត់ពណ៌ខៀវទឹកប៊ិក អក្សរពណ៌សដេរភ្ជាប់លើហោប៉ៅអាវខាងស្ដាំ។

៣- សញ្ញាថ្នាក់ឧត្តមសេនីយ៍និងឧត្តមនាវីលើ កអាវ

ស្លាកសញ្ញាសម្រាប់ថ្នាក់ឧត្តមសេនីយ៍និងឧត្តមនាវីគ្រប់លំដាប់ថ្នាក់មានតែមួយប្រភេទ។

រូបភាពៈ មានរាងដូចស្លែងក្របី ផ្នែកខាងលើមានម្កុដតំណាងឲ្យប្រជាជាតិខ្មែរ ផ្នែកខាងក្រោមមានលំពែង ស្លាបសត្វ និងយុថ្កាតំណាងឲ្យកងទ័ពទាំងបីប្រភេទ។

ខ្នាតៈ កម្ពស់រូបភាព៥ស.ម ទទឹង៣ស.ម កម្ពស់ម្កុដ ១.៨ស.ម បាតក្រោមម្កុដ១.៣ស.ម កម្ពស់យុថ្កា១.៦ស.ម ចុងផ្លែយុថ្កាពីម្ខាងទៅម្ខាង២ស.ម កម្ពស់លំពែងដោយគិតពីដងយុថ្កា០.៦ស.ម ស្លាបសត្វរាងដូចស្នែងក្របីម្ខាងមានស្លាបបីជាន់ (ជាន់ទី១ស្មើ១១ស្លាប ជាន់ទី២ស្មើ៩ស្លាប ជាន់ទី៣ស្មើ៧ស្លាប) កម្ពស់២៥ម.ម ពីចុងម្ខាងទៅចុងម្ខាង៣៥ម.ម។

សញ្ញានេះផលិតពីលោហធាតុពណ៌មាសកម្រាស់១.៥ម.ម និងផលិតពីក្រណាត់ពណ៌ខ្មៅមានប៉ាក់រូបដូចខាងលើ ពីអំបោះពណ៌មាស។

៤- សម្ភាររួមផ្សំ ត្រូវបានកំណត់សម្ភាររួមផ្សំរបស់ឯកសណ្ឋានកងរាជអាវុធហត្ថដូចខាងក្រោមៈ

៤.១- មួកដែក និងទ្រនាប់ក្នុង សម្រាប់ធ្វើការងារជំនាញ មួកទ្រនាប់ធ្វើពីស្ពាច់ពណ៌ទឹកប៊ិក ជុំវិញមានឆ្នូតពណ៌ស ទំហំទទឹង ៥ស.ម ខាងមុខមានដាក់ព្រះសង្ហារខ្នាតធំ ធ្វើពីលោហធាតុពណ៌មាស នៅសងខាងសរសេរអក្សរ **អ.ហ** ពណ៌ស មានកម្ពស់ ៥ស.ម។

៤.២- ខ្សែកញ្ចែ ខ្សែកញ្ចែធ្វើពីនីឡុង ពណ៌មាស វេញចូលគ្នា៥ផ្លូង ប្រវែង ៥០ស.ម ពាក់ក្នុងប៊ូល

ស្មាខាងស្តាំ បន្លាយទម្លាក់ខ្សែពីរ ប្រវែង ២០ស.ម ហើយដាក់កញ្ចៃក្នុងហោប៉ៅស្តាំ។

៩.៣- ខ្សែក្រវ៉ាត់ធំពាក់ឈៀង (សាំងទៀរ៉ុង) ខ្សែក្រវ៉ាត់ធំ ធ្វើពីនីឡុងពណ៌ស ទំហំ ៦ស.ម មាន ស្រោមកាំភ្លើងខ្លីធ្វើពីស្បែកពណ៌ស ខ្សែពាក់ឈៀងទំហំ៣.៥ស.មពណ៌ស បណ្តោយប្រវែង ១២០ស.ម ពាក់ឈៀងក្នុងប៉ូលស្តាំ។

៩.៤- ប៉ានដៃ (ប្រាសសា)

-ប៉ានដៃធ្វើអំពីស្បែក ផ្ទៃពណ៌ខ្មៅសម្រាប់ពាក់លើដៃអាវឆ្វេង ព័ទ្ធជុំវិញដៃអាវ ទទឹងប្រវែង១១ស.ម និងបណ្តោយ ៤០ស.ម មានបន្លាយពាក់លើប៉ូលស្មាខាងឆ្វេងប្រវែង ១៥ស.ម

-ប៉ានដៃនេះមានពីរបែប ទីមួយចំកណ្តាលសរសេរអក្សរមូល **ត.ឈ** និងទីពីចំកណ្តាលសរសេរ អក្សរមូល **អ.ហា** ដាក់ចំពីខាងលើប៉ានដៃ។

៩.៥- ស្រោមដៃស ស្រោមដៃនីឡុង មួយសម្រាប់កខ្លី មួយសម្រាប់ទៀតកវែង។

៩.៦- ខ្សែក្រវ៉ាត់ធំសម្រាប់បើកម៉ូតូ (កងកិត្តិយស)

-ខ្សែក្រវ៉ាត់ធំធ្វើពីស្បែកពណ៌ស រាងពងក្រពើ ក្បាលខ្សែក្រវ៉ាត់រាងចុងស្រួច ប្រវែង៨ស.ម តែនៅ ចំកណ្តាលរាងពងក្រពើ ដូចគំរូស្លាកសញ្ញាកងរាជអាវុធហត្ថ មានអង្កត់ផ្ចិតរង្វង់ក្រៅប្រវែង ២៥ស.ម អង្កត់ ផ្ចិតរង្វង់ក្នុងប្រវែង ២០ស.ម ចន្លោះប្រវែង ២.៥ស.ម។

រូបភាពស្លាកសញ្ញានិងបរិក្ខាររួមផ្សំនៃកងយោធពលខេមរភូមិន្ទ មានគំរូដូចក្នុងឧបសម្ព័ន្ធទី៨នៃអនុ ក្រឹត្យនេះ។

## ជំពូកទី១០
## ទង់ជ័យកងយោធពលខេមរភូមិន្ទ

**មាត្រា ៤០.-**

ទង់ជ័យកងយោធពលខេមរភូមិន្ទរួមមានដូចខាងក្រោម៖

១- ទង់ជ័យកងយោធពលខេមរភូមិន្ទ

យកគំរូទង់ជាតិព្រះរាជាណាចក្រកម្ពុជាមានប្រាសាទអង្គរវត្តកំពូលបី មានបណ្តោយ ១.៩៥ម៉ែត្រ ទទឹង ១.៤៦២៥ម៉ែត្រ ដងទង់ ២.៨៥ម៉ែត្រ នៅផ្នែកខាងលើជ្រុងខាងដើមមានរូបហនុមានកាន់ព្រះខ័នពណ៌ មាសរូបហនុមានកម្ពស់ ២៥ស.ម ទទឹង ២២ស.ម នៅក្រោមប្រាសាទសរសេរអក្សរពណ៌មាស **កងយោធ ពលខេមរភូមិន្ទ** កម្ពស់អក្សរ ១៥ស.ម ក្បាលដងទង់ស្រួចខាងលើឆ្លាក់រូបម្កុដ មានព្រះខ័នទ្រពណ៌មាស ធ្វើពីលោហធាតុពណ៌មាស នៅក្បាលដងទង់មានរំយោលពីរពណ៌មាស មួយប្រវែង១ម៉ែត្រ មួយទៀត ប្រវែង ១.២៥ម៉ែត្រ ។

២- ទង់ជ័យអគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ

យកទង់ជាតិព្រះរាជាណាចក្រកម្ពុជាមានប្រាសាទអង្គរវត្តកំពូលបី មានបណ្តោយ ១.៩៥ម៉ែត្រ ទទឹង ១.៤៦២៥ម៉ែត្រ ដងទង់ ២.៨៥ម៉ែត្រ។ នៅជ្រុងខាងលើផ្នែកខាងដើមទង់មានសញ្ញាហនុមានទំហំ កម្ពស់រូបភាព ២៥ស.ម ទទឹង ២២ស.ម។ នៅខាងក្រោមប្រាសាទលើផ្ទៃពណ៌ខៀវមានសរសេរអក្សរពណ៌ មាស **អគ្គបញ្ជាការកងយោធពលខេមរភូមិន្ទ** កម្ពស់អក្សរ ១៥ស.ម ។

នៅក្បាលដងទង់ស្រួចខាងលើ ឆ្លាក់រូបម្កុដមានព្រះខ័នទ្រធ្វើពីលោហធាតុពណ៌មាស នៅក្បាល ដងទង់មានរំយោលពីរពណ៌មាស មួយប្រវែង ១ម៉ែត្រ មួយទៀតប្រវែង ១.២៥ម៉ែត្រ។

៣- ទង់ជ័យប្រភេទកងទ័ព ឈោធភូមិភាគ និងថ្នាក់ប្រហាក់ប្រហែល

យកទង់ជាតិព្រះរាជាណាចក្រកម្ពុជាមានប្រាសាទអង្គរវត្តកំពូលបី មានបណ្តោយ ១.៧០ម៉ែត្រ ទទឹង ១.៣៥ម៉ែត្រ ដងទង់២.៨០ម៉ែត្រ។ នៅជ្រុងខាងដើមផ្នែកខាងលើមានរូបសញ្ញាទ័ពជំនាញ កម្ពស់២៥ ស.ម ទទឹង ២២ស.ម ពណ៌មាស។ នៅខាងក្រោមប្រាសាទសរសេរអក្សរពណ៌មាស ឈ្មោះកងឯកភាពនីមួយៗកម្ពស់អក្សរ១៥ស.ម។ នៅក្បាលដងទង់ស្រួចខាងលើឆ្លាក់រូបម្កុដមានព្រះខ័នទ្រធ្វើពីលោហធាតុពណ៌មាស នៅក្បាលដងទង់មានរំយោលពីរពណ៌មាស មួយប្រវែង ១ម៉ែត្រ មួយទៀតប្រវែង ១.២៥ម៉ែត្រ ដោយឡែកទ័ពអាកាសរូបម្កុដមានស្លាបសត្វទ្រ និងទ័ពជើងទឹកមានយុថ្កាទ្រពីក្រោម។

៤- ទង់ជ័យថ្នាក់កងពលធំនិងថ្នាក់ប្រហាក់ប្រហែល

យកទង់ជាតិព្រះរាជាណាចក្រកម្ពុជា មានប្រាសាទអង្គរវត្តកំពូល បីមានបណ្តោយ ១.៧០ម៉ែត្រ ទទឹង១.២៧៥ម៉ែត្រ ដងទង់២.៥៥ម៉ែត្រ នៅជ្រុងខាងដើមផ្នែកខាងលើមានរូបទ័ពជំនាញ កម្ពស់២៥ស.ម ទទឹង ២២ ស.ម ពណ៌មាស នៅខាងក្រោមប្រាសាទសរសេរអក្សរពណ៌មាសឈ្មោះកងឯកភាពនីមួយៗ កម្ពស់អក្សរ ១៥ស.ម ។ នៅក្បាលដងទង់ស្រួចខាងលើ ឆ្លាក់រូបម្កុដមានព្រះខ័នទ្រធ្វើពីលោហធាតុពណ៌មាស នៅក្បាលដងទង់មានរំយោលពីរពណ៌មាស មួយប្រវែង ១ម៉ែត្រ មួយទៀតប្រវែង ១.២៥ម៉ែត្រ។ ដោយឡែកទ័ពអាកាសរូបម្កុដមានស្លាបសត្វទ្រ និងទ័ពជើងទឹកមានយុថ្កាទ្រពីក្រោម។

៥- ទង់ជ័យថ្នាក់កងពលតូច តំបន់ប្រតិបត្តិការសឹក វរសេនាធំ និងថ្នាក់ប្រហាក់ប្រហែល

យកទង់ជាតិព្រះរាជាណាចក្រកម្ពុជា មានប្រាសាទអង្គរវត្តកំពូលបី មានបណ្តោយ ១.៦០ម៉ែត្រ ទទឹង ១.២០ម៉ែត្រ ដងទង់២.៤០ម៉ែត្រ។ នៅជ្រុងខាងដើមផ្នែកខាងលើ មានរូបសញ្ញាទ័ពជំនាញពណ៌មាស មានកម្ពស់២៥ស.ម ទទឹង២២ស.ម ខាងក្រោមប្រាសាទអង្គរវត្តសរសេរអក្សរពណ៌មាសឈ្មោះកងឯកភាពនីមួយៗ កម្ពស់អក្សរ ១៥ស.ម។ នៅក្បាលដងទង់ស្រួចខាងលើឆ្លាក់រូបព្រះខ័នធ្វើពីលោហធាតុពណ៌មាស នៅក្បាលដងទង់មានរំយោល២ពណ៌មាស មួយប្រវែង១ម៉ែត្រ មួយទៀតប្រវែង១.២៥ម៉ែត្រ។ ដោយឡែកទ័ពអាកាស រូបម្កុដមានស្លាបទ្រពីក្រោមម្កុដ និងទ័ពជើងទឹកមានរូបយុថ្កាទ្រពីក្រោម។

៦- ទង់ជ័យសម្រាប់សម្គាល់កងឯកភាព កងរាជអាវុធហត្ថ មាន៣ប្រភេទដូចខាងក្រោម៖

៦.១- ទង់ជ័យកងរាជអាវុហត្ថលើផ្ទៃប្រទេស យកតាមគំរូទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជា ប្រាសាទអង្គរវត្តកំពូល៣ មានបណ្តោយ ១.៨០ម៉ែត្រ ទទឹង ១.៣៥ម៉ែត្រ ដងទង់ប្រវែង ២.៨០ម៉ែត្រ នៅជ្រុងខាងដើមផ្នែកខាងលើមានរូបស្លាកសញ្ញាកងរាជអាវុធហត្ថ ពណ៌មាស អក្សរ **កងរាជអាវុធហត្ថ** កម្ពស់ ១០ស.ម នៅក្បាលដងទង់ស្រួច ខាងលើស្លាកម្កុដ រូបម្កុដពណ៌មាស និងខាងក្រោមមានស្លាកសញ្ញាកងរាជអាវុធហត្ថធ្វើពីលោហធាតុពណ៌មាស នៅកណ្តាលដងទង់មានរំយោលពីរពណ៌មាស រំយោលមួយប្រវែង ១ម៉ែត្រ មួយទៀតប្រវែង១.២៥ម៉ែត្រ ធ្វើពីក្រណាត់នីឡុងពណ៌ទឹកមាស ជុំវិញទង់ជ័យលើជ្រុងទាំង៣មាន រំយោលពណ៌មាសប្រវែង ១០ស.ម។

៦.២- ទង់ជ័យសម្រាប់សម្គាល់តាមកងឯកភាពចំណុះ រូបភាពដូចគ្នា តែខុសត្រង់បណ្តោយប្រវែង ១.៧០ម៉ែត្រ ទទឹង ១.២៥ម៉ែត្រ ដងទង់ប្រវែង ២.៥៥ម៉ែត្រ នៅជ្រុងខាងដើមផ្នែកខាងលើមានស្លាកសញ្ញាពណ៌មាសសម្រាប់អង្គភាព មានអង្កត់ផ្ចិត ០.៦៨ស.ម នៅខាងក្រោមប្រាសាទសរសេរអក្សរពណ៌មាស ឈ្មោះកងឯកភាពមានកម្ពស់ ១០ស.ម។

៦.៣-ទង់រាងត្រីកោណ មានបាត២០ស.ម កម្ពស់ ៣០ស.ម រូបភាពពណ៌ រត់តាមបន្ទាត់ បាតទង់ខាងលើនិងខាងក្រោមប្រវែង ៥ស.មមានពណ៌ខៀវ កណ្តាល១០ស.ម ពណ៌ក្រហមនៅចំកណ្តាលដាក់

ស្លាកកងឯកភាព។

**មាត្រា ៤១.-**

បែបបទនៃការប្រើប្រាស់ទង់ជ័យរបស់កងយោធពលខេមរភូមិន្ទ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ។

## ជំពូកទី១១
## ការប្រើប្រាស់និងការធានា

**មាត្រា ៤២.-**

យោធិននៃកងយោធពលខេមរភូមិន្ទត្រូវស្លៀកពាក់ឯកសណ្ឋានតាមការកំណត់នៃអនុក្រឹត្យនេះ។ ការស្លៀកពាក់មិនបានត្រឹមត្រូវតាមការកំណត់ ត្រូវចាត់ទុកថាជាការល្មើសនឹងវិន័យរបស់កងយោធពលខេមរភូមិន្ទ។

**មាត្រា ៤៣.-**

រាល់ការផលិតឯកសណ្ឋាននិងបរិក្ខាររួមផ្សំរបស់កងយោធពលខេមរភូមិន្ទ ត្រូវមានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងការពារជាតិ។ ការស្តុក ការជួញដូរ ការផលិត គ្មានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវផ្តន្ទាទោសតាមច្បាប់។

ក្នុងករណីមានជំនួយពីបរទេសអំពីឯកសណ្ឋានឬយោធបរិក្ខារផ្សេងៗ ខុសពីការកំណត់នៃអនុក្រឹត្យនេះប្រើប្រាស់បានលុះត្រាតែមានការអនុញ្ញាតជាផ្លូវការពីរដ្ឋមន្ត្រីក្រសួងការពារជាតិ។

**មាត្រា ៤៤.-**

សញ្ញាសម្គាល់កងឯកភាព ស្ថាប័នចំណុះក្រសួងការពារជាតិ និងអគ្គបញ្ជាការនៃកងយោធពលខេមរភូមិន្ទសម្រាប់ដេរភ្ជាប់លើដៃអាវខាងឆ្វេងនៃឯកសណ្ឋានលេខ៤ លេខ៥ និងបិទលើយានយន្ត សញ្ញាសម្គាល់វគ្គសិក្សាក្នុងនិងក្រៅប្រទេស ការណែនាំអំពីការប្រើប្រាស់ឯកសណ្ឋាន ស្លាកសញ្ញាគ្រប់ប្រភេទរបស់កងយោពលខេមរភូមិន្ទ ការប្រើប្រាស់ចំនួនកងត្រែទ័ព កងកិត្តិយស ព្រមទាំងគោលរបបសម្រាប់បើកចែកជូនយោធិន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ។

## ជំពូកទី១២
## អវសានប្បញ្ញត្ត

**មាត្រា ៤៥.-**

អនុក្រឹត្យលេខ០៧អនក្រ.បក ចុះថ្ងៃទី២១ ខែមករា ឆ្នាំ១៩៩៧ស្តីពីការរៀបចំឯកសណ្ឋាន ផ្លាកសញ្ញា និងទង់ជ័យនៃកងយោធពលខេមរភូមិន្ទ អនុក្រឹត្យលេខ០៩អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ ស្តីពីវិសោធនកម្មនៃអនុក្រឹត្យលេខ០៧អនក្រ.បក ចុះថ្ងៃទី២១ ខែមករា ឆ្នាំ១៩៩៧ ត្រង់មាត្រា ១,២,៣និងមាត្រា៨ អនុក្រឹត្យលេខ៨៦អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០១ ស្តីពីការកែសម្រួលបង្កើតផ្លាកសញ្ញាមួយចំនួន បំពេញបន្ថែមលើមាត្រា៦នៃអនុក្រឹត្យលេខ០៧អនក្រ.បក ចុះថ្ងៃទី២១ ខែមករា ឆ្នាំ១៩៩៧ស្តីពីការរៀបចំឯកសណ្ឋាន ផ្លាកសញ្ញានិងទង់ជ័យនៃកងយោធពលខេមរភូមិន្ទ អនុក្រឹត្យលេខ៥៥អនក្រ.បកចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៣ ស្តីពីការកែសម្រួលផ្លាកសញ្ញារូបហនុមាន សញ្ញាកងឯកភាពឧត្រយោង ឯកសណ្ឋានការងារលេខ៤ មួកបោនណេ ការស្លៀកពាក់ឯកសណ្ឋានការងារលេខ៤ និងសញ្ញាអគ្គបញ្ជាការ កងទ័ពជើងគោក ជើងទឹក ជើងអាកាស និងរូបសញ្ញាក្រសួងការពារជាតិ អនុក្រឹត្យលេខ៨១អនក្រ.បកចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៤ ស្តីពីការកែសម្រួលផ្លាកសញ្ញាសម្រាប់ពាក់លើមួក ផ្លាក-

សញ្ញាសម្រាប់ថ្នាក់ ឧត្តមសេនីយ៍ និងឯកសណ្ឋានការងារលេខ៥នៃអនុក្រឹត្យលេខ០៧អនក្រ.បក ចុះថ្ងៃទី-២១ ខែមករា ឆ្នាំ១៩៩៧ និងអនុក្រឹត្យលេខ៨៥អនក្រ.បកចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៣ អនុក្រឹត្យលេខ ២២អនក្រ.បកចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំឯកសណ្ឋាន និងសក្តិរបស់កម្មសិក្សានាយទាហាន អនុក្រឹត្យលេខ២៦អនក្រ.បកចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ១៩៩៨ ស្តីពីឯកសណ្ឋាន និងផ្លាកសញ្ញាកងរាជអាវុធហត្ថ និងអនុក្រឹត្យលេខ៦៦អនក្រ.បកចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ស្តីពីការកែសម្រួលសញ្ញាកងវិស្វកម្មនៃកងយោធពលខេមរភូមិន្ទ នៃអនុក្រឹត្យលេខ០៧អនក្រ.បកចុះថ្ងៃទី២១ ខែមករា ឆ្នាំ១៩៩៧ និងបទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា ៤៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

**សម្តេចអគ្គមហាសេនាបតីតេជោ**

**នាយករដ្ឋមន្ត្រី** សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងការពារជាតិ**

**នាយឧត្តមសេនីយ៍ ទៀ បាញ់**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា៤៦
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធទី១** នៃអនុក្រឹត្យលេខ..១៤៧..អនក្រ..បក..ចុះថ្ងៃទី.....១១.....ខែ..កុម្ភៈ.....ឆ្នាំ..២០១៧

ស្ដីពីឯកសណ្ឋាន ស្លាកសញ្ញា និងទង់ជ័យនៃកងយោធពលខេមរភូមិន្ទ

**ឯកសណ្ឋានធំលេខ១ អាវក្មួជ (កងទ័ពជើងគោក)**

**ឧត្តមសេនីយ៍** **វរសេនីយ៍** **អនុសេនីយ៍**



**ឯកសណ្ឋានធំលេខ២ អាវវ៉ារ៉ឺ (កងទ័ពជើងគោក)**

**ឧត្តមសេនីយ៍** **វរសេនីយ៍** **អនុសេនីយ៍** **[illegible]**



## ឯកសណ្ឋានធំលេខ៣ សាហារីយែន (កងទ័ពជើងគោក)

ឧត្តមសេនីយ៍ វរសេនីយ៍ អនុសេនីយ៍



## ឯកសណ្ឋានលេខ៤ ការងារដៃវែង (កងទ័ពជើងគោក)

ឧត្តមសេនីយ៍ វរសេនីយ៍ អនុសេនីយ៍ នាយទាហានរង និងពលទាហាន



## ឯកសណ្ឋានលេខ៤ ការងារដៃវែង (កងទ័ពជើងគោក)

ឧត្តមសេនីយ៍ | វរសេនីយ៍ | អនុសេនីយ៍ | នាយទាហានរង និងពលទាហាន



## ឯកសណ្ឋានលេខ៥ ប្រយុទ្ធប៉ារ៉ា (កងទ័ពជើងគោក)

ឧត្តមសេនីយ៍ | វរសេនីយ៍ | អនុសេនីយ៍ | នាយទាហានរង និងពលទាហាន



## ឯកសណ្ឋានលេខ៥ ប្រយុទ្ធប៉ារ៉ា (កងទ័ពជើងគោក)

ទ័ពពិសេសឆត្រយោង ប៉ារ៉ាក្រឡាតូច | កងការពារព្រំដែន | មជ្ឈមណ្ឌលជាតិគ្រប់គ្រងកងកម្លាំងរក្សាសន្តិភាព បោសសម្អាតមីន និងកាកសំណល់សង្គ្រាម





## ឯកសណ្ឋានបច្ចេកទេស (កងទ័ពជើងគោក)

គ្រឿងយន្តចក្រកម្ម | រថក្រោះ-រថពាសដែក



## ឯកសណ្ឋានលេខ៥ ប្រយុទ្ធប៉ារ៉ា (កងទ័ពជើងគោក)

ឧត្តមសេនីយ៍ | វរសេនីយ៍ | អនុសេនីយ៍ | នាយទាហានរង និងពលទាហាន



## ឯកសណ្ឋានលេខ៥ ប្រយុទ្ធប៉ារ៉ា (កងទ័ពជើងគោក)

ឧត្តមសេនីយ៍ | វរសេនីយ៍ | អនុសេនីយ៍ | នាយទាហានរង និងពលទាហាន



## សញ្ញាលើហោប៉ៅអាវស្តាំ

សញ្ញាក្រសួង



សញ្ញាជើងគោក



សញ្ញាអគ្គបញ្ជាការ



## សញ្ញាលោហធាតុលើ កអាវ

សញ្ញាថ្មើរជើង



សញ្ញាចលនូបត្ថម្ភ



សញ្ញាសុខាភិបាល



សញ្ញាភូមិសាស្ត្រយោធា



សញ្ញាកាំភ្លើងធំ-ការពារដែនអាកាស



សញ្ញារថក្រោះ-រថពាសដែក



សញ្ញាបញ្ជូនសារ



សញ្ញាវិស្វកម្ម



សញ្ញាកងឯកភាពសាលា



សញ្ញាតុលាការយោធា



សញ្ញាអយ្យការយោធា



សញ្ញាសិល្បៈ-ត្រែទ័ព



សញ្ញាបច្ចេកទេសទី១



សញ្ញាបច្ចេកទេសទី២



សញ្ញាទ័ពពិសេសឆត្រយោង



សញ្ញាដឹកជញ្ជូន



**ឧបសម្ព័ន្ធទី២** នៃអនុក្រឹត្យលេខ..១៤..អនក្រ.បក..ចុះថ្ងៃទី..០១......ខែ.កុម្ភៈ......ឆ្នាំ.២០១៧.

ស្តីពីឯកសណ្ឋាន ស្លាកសញ្ញា និងទង់ជ័យនៃកងយោធពលខេមរភូមិន្ទ

**ឯកសណ្ឋានធំលេខ១ អាវកុដ (កងទ័ពជើងទឹក)**

**ឧត្តមនាវ** **វរនាវ** **អនុនាវ**



**ឯកសណ្ឋានធំលេខ២ អាវអ៉ាវ៉ឺ (កងទ័ពជើងទឹក)**

**ឧត្តមនាវ** **វរនាវ** **អនុនាវ** **បេសកកម្មក្រៅប្រទេស**



**ឯកសណ្ឋានធំលេខ៣ សមាហារីយែន (កងទ័ពជើងទឹក)**

ឧត្តមនាយ វរនាយ អនុនាយ



**ឯកសណ្ឋានលេខ៤ ការងារដៃខ្លី (កងទ័ពជើងទឹក)**

ឧត្តមនាយ វរនាយ អនុនាយ នាយទាហានរង និងពលទាហាន



## ឯកសណ្ឋានលេខ៥ ប្រយុទ្ធប៉ាក៉ាខ្សាច់ (កងទ័ពជើងទឹក)

ឧត្តមនាវី វរនាវី អនុនាវី នាយនាវីរង និងពលនាវី



## ឯកសណ្ឋានលេខ៥ ប្រយុទ្ធប៉ាក៉ាខ្សាច់ (កងទ័ពជើងទឹក)

ឧត្តមនាវី វរនាវី អនុនាវី នាយនាវីរង និងពលនាវី



## ឯកសណ្ឋានលេខ៥ ប្រយុទ្ធប៉ាអ៊ាខ្សាច់ (កងទ័ពជើងទឹក)

ឧត្តមនាវី | វរនាវី | អនុនាវី | នាយនាវីរង និងពលនាវី



## ឯកសណ្ឋានបច្ចេកទេស (កងទ័ពជើងទឹក)

គ្រឿងយន្តនាវាចរ | គ្រឿងយន្តនាវាចរ



សញ្ញាលើហោប៉ៅអាវស្តាំ



សញ្ញាលោហធាតុលើ កអាវ



**ឧបសម្ព័ន្ធទី៣** នៃអនុក្រឹត្យលេខ..២៤..អនក្រ.បក.ចុះថ្ងៃទី..០២......ខែ..កុម្ភៈ.....ឆ្នាំ២០១៧..

ស្តីពីឯកសណ្ឋាន ស្លាកសញ្ញា និងទង់ជ័យនៃកងយោធពលខេមរភូមិន្ទ

**ឯកសណ្ឋានធំលេខ១ អាវកុដ (កងទ័ពជើងអាកាស)**

**ឧត្តមសេនីយ៍** **វរសេនីយ៍** **អនុសេនីយ៍**



**ឯកសណ្ឋានធំលេខ២ អាវវ៉ារី (កងទ័ពជើងអាកាស)**

**ឧត្តមសេនីយ៍** **វរសេនីយ៍** **អនុសេនីយ៍** **បេសកកម្មក្រៅប្រទេស**



## ឯកសណ្ឋានធំលេខ៣ សាហារីយ៉ែន (កងទ័ពជើងអាកាស)

ឧត្តមសេនីយ៍ វរសេនីយ៍ អនុសេនីយ៍



## ឯកសណ្ឋានលេខ៤ ការងារដៃវែង (កងទ័ពជើងអាកាស)

ឧត្តមសេនីយ៍ វរសេនីយ៍ អនុសេនីយ៍ នាយទាហានរង
និងពលទាហាន



## ឯកសណ្ឋានលេខ៥ ប្រយុទ្ធប៉ារ៉ា (កងទ័ពជើងអាកាស)

ឧត្តមសេនីយ៍ | វរសេនីយ៍ | អនុសេនីយ៍ | នាយទាហានរង និងពលទាហាន



## ឯកសណ្ឋានលេខ៥ ប្រយុទ្ធប៉ារ៉ា (កងទ័ពជើងអាកាស)

ឧត្តមសេនីយ៍ | វរសេនីយ៍ | អនុសេនីយ៍ | នាយទាហានរង និងពលទាហាន



## ឯកសណ្ឋានលេខ៥ ប្រយុទ្ធប៉ារ៉ា (កងទ័ពជើងអាកាស)

ឧត្តមសេនីយ៍ វរសេនីយ៍ អនុសេនីយ៍ នាយទាហានរង និងពលទាហាន



## ឯកសណ្ឋានបច្ចេកទេស (កងទ័ពជើងអាកាស)

ប្រភេទឧទ្ធម្ភាគចក្រ គ្រឿងយន្តអាកាសចរ



សញ្ញាលើហោប៉ៅអាវស្តាំ



សញ្ញាលោហធាតុលើកអាវ



**ឧបសម្ព័ន្ធទី៤** នៃអនុក្រឹត្យលេខ១២៤.អនក្រ.បក.ចុះថ្ងៃទី............ខែ.កុម្ភៈ......ឆ្នាំ២០១៧...
ស្តីពីឯកសណ្ឋាន ស្លាកសញ្ញា និងទង់ជ័យនៃកងយោធពលខេមរភូមិន្ទ

**ឯកសណ្ឋានកម្មសិក្សានាយទាហាន**



**សក្ក នាយទាហានសកម្ម**




**សក្ក នាយទាហានទ័ពជើងគោក**



**ឧបសម្ព័ន្ធទី៥** នៃអនុក្រឹត្យលេខ.១២.អនក្រ.បក.ចុះថ្ងៃទី...០១.....ខែ...កុម្ភៈ...ឆ្នាំ.២០១៧

ស្ដីពីឯកសណ្ឋាន ស្លាកសញ្ញា និងទង់ជ័យនៃកងយោធពលខេមរភូមិន្ទ

**ឯកសណ្ឋាន ប្រយុទ្ធអាវជាប់ខោពណ៌ខ្មៅ (កម្លាំងពិសេសប្រឆាំងភេរវកម្ម)**

**មួកហ៊ៀកកខ្មៅ** **មួកបេរ៉េពណ៌ខ្សាច់ចាស់**





**ឯកសណ្ឋានលេខ៥ ប្រយុទ្ធប៉ារ៉ា (កម្លាំងពិសេសប្រឆាំងភេរវកម្ម)**

**មួកហ៊ៀកកខ្មៅ** **មួកបេរ៉េពណ៌ខ្សាច់ចាស់**





## សញ្ញាលើហោប៉ៅអាវស្តាំ



**ឧបសម្ព័ន្ធទី៦** នៃអនុក្រឹត្យលេខ..១២៤..អនក្រ.បក..ចុះថ្ងៃទី..០១.......ខែ.កុម្ភៈ.....ឆ្នាំ.២០១៧

ស្តីពីឯកសណ្ឋាន ស្លាកសញ្ញា និងទង់ជ័យនៃកងយោធពលខេមរភូមិន្ទ

**ឯកសណ្ឋានធំលេខ១ អាវក្នុង (កងរាជអាវុធហត្ថ)**

**ឧត្តមសេនីយ៍** **វរសេនីយ៍** **អនុសេនីយ៍**



**ឯកសណ្ឋានធំលេខ២ អាវវ៉ារ៉ឺ (កងរាជអាវុធហត្ថ)**

**ឧត្តមសេនីយ៍** **វរសេនីយ៍** **អនុសេនីយ៍** **បេសកកម្មក្រៅប្រទេស**



## ឯកសណ្ឋានធំលេខ៣ សាហារីយែន (កងរាជអាវុធហត្ថ)

ឧត្តមសេនីយ៍ វរសេនីយ៍ អនុសេនីយ៍



## ឯកសណ្ឋានលេខ៤ ការងារដៃវែង (កងរាជអាវុធហត្ថ)

ឧត្តមសេនីយ៍ វរសេនីយ៍ អនុសេនីយ៍ នាយទាហានរង និងពលទាហាន



## ឯកសណ្ឋាន ជំនាញអាវុធហត្ថ

មួកស៊ីកាស មួកបេរ៉េពណ៌ខៀវទឹកប៊ិក



## ឯកសណ្ឋានលេខ៥ ប្រយុទ្ធពណ៌ខៀវទឹកប៊ិកចាស់ (កងរាជអាវុធហត្ថ)

ឧត្តមសេនីយ៍ វរសេនីយ៍ អនុសេនីយ៍ នាយទាហានរង និងពលទាហាន



## ឯកសណ្ឋានលេខ៥ ប្រយុទ្ធពណ៌ខៀវទឹកប៊ិកចាស់ (កងរាជអាវុធហត្ថ)

ឧត្តមសេនីយ៍ វរសេនីយ៍ អនុសេនីយ៍ នាយទាហានរង និងពលទាហាន



## ឯកសណ្ឋាន កងយានយន្តកត្តយស (កងរាជអាវុធហត្ថ)

រូបខាងមុខ រូបខាងក្រោយ



សក្តិ និងសញ្ញាប៉ាក់លើ កអាវ



សញ្ញាលោហធាតុលើ កអាវ



សញ្ញាលោហធាតុលើ កអាវ



**ឧបសម្ព័ន្ធទី៧** នៃអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១៧
ស្តីពីឯកសណ្ឋាន ស្លាកសញ្ញា និងទង់ជ័យនៃកងយោធពលខេមរភូមិន្ទ

## ឯកសណ្ឋានកងត្រៃទ័ព និងកងកិត្តិយស

**ជើងគោក** **ជើងទឹក** **ជើងអាកាស** **កងត្រៃ** **កងដាវ**



## សក្តិកងត្រៃទ័ព និងកងកិត្តិយស



**ឯកសណ្ឋានសម្រាប់បុណ្យសព**



**ឧបសម្ព័ន្ធទី៨** នៃអនុក្រឹត្យលេខ...១៤២ អនក្រ.បក...ចុះថ្ងៃទី...០១......ខែ...កុម្ភៈ....ឆ្នាំ២០១៧

ស្តីពីឯកសណ្ឋាន ស្លាកសញ្ញា និងទង់ជ័យនៃកងយោធពលខេមរភូមិន្ទ

រូបព្រះសង្ហារលោហធាតុ



រូបព្រះសង្ហារប៉ាក់



សញ្ញានៅលើដៃអាវស្តាំ



សញ្ញាហនុមាន



សញ្ញាលោហធាតុលើ កអាវ
ថ្នាក់ឧត្តមសេនីយ៍





ផ្លាកឈ្មោះជ័រ



ផ្លាកឈ្មោះ ឯកសណ្ឋានលេខ៥



ផ្លាកឈ្មោះជ័រ (កងរាជអាវុធហត្ថ)




ផ្លាកឈ្មោះ (ឯកសណ្ឋានលេខ៥ អហ)



មួកស៊ីកាស អហ



កញ្ចែ+ខ្សែពណ៌លឿង



ខ្សែក្រវាត់ពាក់ឈៀង ស



កងឯកភាពតម្រួតយោធា




កងរាជអាវុធហត្ថ




ស្រោមដៃ ស



ខ្សែក្រវាត់កងយានយន្តកិត្តិយស

